## តើរង់ចាំដល់ពេលណា?

កើតមកជាមនុស្សសែនសំណាង ព្រោះតែបានសាងបុណ្យកុសលមក
មុនពេលដែលខ្លួនបានចុះយោនយក សុំទីជម្រកក្នុងផ្ទៃមាតា ។
បុណ្យកុសលជាទ្រព្យគាប់ប្រសើរ អាចរួមដំណើរនៅថ្ងៃមរណា
នៅពេលរូបយើងរំលាយសង្ខារ បែកធ្លាយកាយាពីលោកនេះទៅ ។
ដូច្នេះតើយើងរង់ចាំដល់ណា ទើបបែរភក្ត្រាមកកាន់ផ្លូវត្រូវ
ចាប់យកសីលទានធ្វើជាសំពៅ ចម្លងយើងទៅដល់ទីសុខសាន្ត ។
ធ្វើដំណើរតាមមគ្គអង្គប្រាំបី ដែលព្រះជិនស្រីព្រះអង្គទ្រង់បាន
សម្តែងប្រទានប្រាប់យើងគ្រប់ប្រាណ គ្រប់ស្រុកភូមិឋាននៅក្នុងលោកា ។
សមាទិដ្ឋិសមាសង្កប្បៈ ទាំងពីរជាថ្នាក់តួអង្គបញ្ញា
សមាអាជីវៈ សមាវាចា សមាកម្មន្តានេះជាតួសីល ។
សមាវាយាមៈ សមាសតិ សមាសមាធិជាតួផ្តាច់ផ្តិល
ផ្តាច់បង់កិលេសឱ្យរលីងស្រិល ឱ្យអស់មន្ទិលពីចិត្តសន្តាន ។
ផ្លូវទាំងនេះនាំងសត្វរួចពីទុក្ខ រស់នៅដោយសុខគ្រប់ភូមិឋាន
ជាផ្លូវនាំសត្វមានតែកល្យាណ សន្តោសប្រោសប្រាណដល់គ្នានឹងគ្នា ។

ដោយភិក្ខុបញ្ញាវរោ **ស៊ុយ សុវណ្ណ**

ឧបត្ថម្ភដោយ
មិត្តពុទ្ធសាសនិកម៉ាឡេស៊ី
សម្រាប់ចែកជាធម្មទានប៉ុណ្ណោះ

Sponsored by
Malaysian Buddhist Friends
For Free Distribution Only

មាគ៌ាព្រះពុទ្ធសាសនា ព្រះតេជគុណបណ្ឌិត ក. ស្រីធម្មានន្ទ

# មាគ៌ាព្រះពុទ្ធសាសនា

# The Buddhist Way

ព្រះតេជគុណបណ្ឌិត ក. ស្រីធម្មានន្ទ
Venerable Dr. K. Sri Dhammananda

ព.ស. ២៥៥៤

# មាគ៌ាព្រះពុទ្ធសាសនា

**និពន្ធដោយ**

**ព្រះតេជគុណ បណ្ឌិត ក. ស្រីធម្មានន្ទ**

**ប្រែនិងរៀបរៀងដោយ**

**ភិក្ខុ ព្រំ ស៊ីណា (សព្វោគតវីរិយោ)**


**បោះពុម្ពលើក១**

ចំនួន ៤.០០០ ក្បាល

**ការផ្សាយរបស់**

**សមាគមសមណនិស្សិតខ្មែរ**

ទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា

**ឧបត្ថម្ភបោះពុម្ពដោយ**

**មិត្តពុទ្ធសាសនិកម៉ាឡេស៊ី**

សម្រាប់ចែកជាធម្មទានប៉ុណ្ណោះ

**ព.ស. ២៥៥៤**

# THE BUDDHIST WAY

By
Venerable Dr. K. Sri Dhammananda

Translated and Prepared by
Bhikkhu Prum Sina (Sañjātavīviyo)

First Edition
4,000 copies

A Publication of
Cambodian Buddhist Student-Monks
Yangon, Myanmar

Sponsored by:
Malaysian Buddhist Friends
For Free Distribution Only

B.E. 2554

ឈ្មោះសៀវភៅ : **មាគ៌ាព្រះពុទ្ធសាសនា**
The Buddhist Way

អ្នកបកប្រែ : ភិក្ខុសញ្ជាតវីរិយោ **ព្រុំ ស៊ីណា**
Bhikkhu Sañjātavīviyo Prum Sina
E-mail: prumsina@gmail.com
Website: http://info-ksma.wikidot.com
http://info-ksma.blogspot.com

បោះពុម្ពលើកទី១ : នៅថ្ងៃពុធ ១ កើត ខែស្រាពណ៍ ឆ្នាំ ខាល ព.ស.
២៥៥៤ ត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០

ចំនួនបោះពុម្ព : ៤០០០ ក្បាល
Amount : 4,000 copies
តម្លៃ (Cost) : ……………………………

អ្នកឧបត្ថម្ភ : **មិត្តពុទ្ធសាសនិកម៉ាឡេស៊ី**
Donors : Malaysian Buddhist Friends

បោះពុម្ពដោយ : **រោងពុម្ព ម៉េង ហាវ**
ផ្ទះលេខ ៨១ ផ្លូវ១៧២ សង្កាត់ជ័យជំនះ
ខណ្ឌដូនពេញ ក្រុងភ្នំពេញ ទូរស័ព្ទ ០១២ ៨២៦ ៩២០

ផ្សាយចេញពី : **សមាគមសមណនិស្សិតខ្មែរ**
សាកលវិទ្យាល័យធម្មទូត សហភាពមីយ៉ាន់ម៉ា

# មាតិការឿង

ទំព័រ


អារម្ភកថាអ្នកបកប្រែ.............................................................. ក

សេចក្តីថ្លែងអំណរគុណ .............................................................. ខ

សេចក្តីផ្តើម .............................................................. ឃ

កាតព្វកិច្ចមាតាបិតាក្នុងការអប់រំបុត្រធីតា .............................................................. ១

ពិធីមង្គលសម្រាប់បុត្រធីតា .............................................................. ៥

ហេតុអ្វីបានជាយើងសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក? .............................................................. ៦

ការអប់រំបែបព្រះពុទ្ធសាសនា និងការប្រតិបត្តិតាមវប្បធម៌ .............................................................. ១០

ពិធីអាពាហ៍ពិពាហ៍ .............................................................. ១៣

ពិធីបុណ្យសាសនា .............................................................. ១៦

ប្រពៃណី ឬសាសនាដែលហាមប៉ះពាល់ .............................................................. ១៨

មន្តស្នេហ៍ និងអំពើអាបធ្មប់ .............................................................. ២០

រូបបដិមា ទឹកមន្ត អំបោះមន្ត គ្រឿងវេទមន្ត និងវត្ថុស័ក្តិសិទ្ធិ .............................................................. ២៤

ជម្ងឺ .............................................................. ២៧

ការស្លាប់ .............................................................. ៣១

ការវះកាត់ពិនិត្យសាកសព .............................................................. ៣៥

ពិធីបុណ្យសព .............................................................. ៣៧

ការកប់ និងការបូជាសព .............................................................. ៤៦

ការយកសំណល់អដ្ឋិធាតុទៅចោល .............................................................. ៤៨

រយៈពេលនៃការកាន់ទុក្ខ .............................................................. ៥១

ពិធីបុណ្យក្រោយពិធីបុណ្យសព និងពិធីបុណ្យខួប .............................................................. ៥៣

ការធ្វើទាន .............................................................. ៥៥

សន្និដ្ឋាន .............................................................. ៥៧

# អារម្ភកថាអ្នកបកប្រែ

នៅក្នុងសង្គមនីមួយៗមានការប្រតិបត្តិមិនដូចគ្នាទេ។ ការប្រតិបត្តិគឺអាស្រ័យទៅតាមជំនឿនៃប្រជាជនក្នុងតំបន់ ឬប្រទេសនីមួយៗនោះ។ ប៉ុន្តែទោះបីជាយ៉ាងណា មនុស្សគ្រប់រូបសុទ្ធតែប្រាថ្នាចង់បាននូវសេចក្ដីសុខចម្រើន មិនថាពួកគាត់កំពុងតែប្រតិបត្តិនូវជំនឿអ្វីនោះឡើយ។ មាគ៌ានៃការប្រតិបត្តិខ្លះហាក់បីជាមានប្រយោជន៍ ចំណែកឯមាគ៌ាខ្លះទៀតបានបង្កនូវភាពសោកសៅដល់មនុស្សកាន់ច្រើនឡើងៗ។ ចុះតើមាគ៌ាព្រះពុទ្ធសាសនាវិញដូចម្ដេចដែរ? តើអ្នកដែលសាកល្បងធ្វើតាមអ្វីដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងប្រាប់ដែរទេ? តើអ្នកធ្លាប់ស្គាល់មាគ៌ាប្រកដោយអង្គប្រាំបីប្រការឬទេ? មាគ៌ាព្រះពុទ្ធសាសនា គឺជាមាគ៌ាឯកដែលអាចនាំមនុស្សឱ្យរួចផុតពីជំនឿបោកប្រាស់ ជាមាគ៌ាដែលយកបញ្ញាធ្វើត្រីមុខ។ គ្រប់ការប្រតិបត្តិនូវជំនឿត្រូវតែប្រកបដោយបញ្ញា ដើម្បីធានាថា អាចចៀសផុតពីសេចក្ដីទុក្ខសោកសៅក្ដៅក្រហាយក្នុងចិត្ត។

ដូច្នេះ ដើម្បីឱ្យរឹងរឹតតែជាក់ពីមាគ៌ាប្រតិបត្តិនៅក្នុងព្រះពុទ្ធសាសនា ខ្ញុំសូមឧទ្ទិសកូនសៀវភៅនេះ ចំពោះមិត្តអ្នកអានទាំងឡាយដែលកំពុងតែខ្នះខ្នែងស្វះស្វែងរកនូវមាគ៌ាប្រតិបត្តិ ដើម្បីសេចក្ដីសុខចម្រើនក្នុងជីវិតប្រចាំថ្ងៃ។ សូមមិត្តអ្នកអានទាំងឡាយជួបប្រទះនូវមាគ៌ាដ៏ប្រពៃក្នុងជីវិត!



# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំព្រះករុណាអាត្មាភាព សូមសម្ដែងនូវកតញ្ញូតាធម៌ដឹងគុណ និងអរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ :

- ព្រះតេជគុណ **ហួរ សុខវឌ្ឍ** ប្រធានសមាគមពុទ្ធសាសនា និងអភិវឌ្ឍន៍សង្គមសាខាខេត្ត តាកែវ ដែលបានជួយចាត់ចែងបោះពុម្ពសៀវភៅ "**មាគ៌ាព្រះពុទ្ធសាសនា**" សម្រាប់ចែកជាធម្មទាន។

- ព្រះតេជគុណវិជ្ជាសម្បន្នោ **ឈួម បូ** ញោមឧបាសិកា **ចយ សារឿន** ញោម **សុវណ្ណី** និងញោមញាតិចំណុះជើងវត្តពន្លឺពុទ្ធចក្កទាំងអស់

- ឧបាសក **ម៉ៅ វ៉ាន** ឧបាសិកា **ឆន់ សំបូរ** អតីតទីប្រឹក្សាឯកអគ្គរាជទូតកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា។

- លោក **យូ បាន** (Mr. Yu Ban) ពីប្រទេសម៉ាឡេស៊ី (Malaysia) ដែលមានសទ្ធាជ្រះថ្លា ក្នុងការខ្នះខ្នែងស្វែងរកថវិកាជួយបោះពុម្ពសៀវភៅ "ហេតុអ្វីបានជាមានពុទ្ធសាសនា?" "*Why Buddhism?*" សៀវភៅ "ខ្លឹមសារជីវិត" "*The Purpose of Life*" សៀវភៅ "គាថាធម្មបទ" (The Dhammapada) និងសៀវភៅ "មាគ៌ាព្រះពុទ្ធសាសនា" "The Buddhist Way", សម្រាប់ចែកជាធម្មទានដល់សា-

ធារណជន និងសូមអរគុណដល់ "មិត្តពុទ្ធសាសនិកម៉ាឡេស៊ី" "All Malaysian Buddhist Friends" and មិត្តសប្បុរសជនចំណុះជើងវត្តមហាវិហារ "Devotees and Friends of Buddhist Mahā Vihāra" ទាំងអស់។

- ញោមឧបាសិកា គិម **ស៊ីមឿន សីលវន្ត សីលវតី** នៅក្នុងពុទ្ធមណ្ឌលវិបស្សនាធុរៈនៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ ដែលតែងតែយកចិត្តទុកជួយឧបត្ថម្ភបច្ច័យបួន និងវត្ថុគ្រប់បែបយ៉ាងដល់សមណនិស្សខ្មែរនៅភូមា។

- ញោមមហាឧបាសិកា **កាំង ហ៊្គិចណៃ** និងក្រុមគ្រួសារ ដែលតែងតែជួយឧបត្ថម្ភដល់សមណនិស្សិតខ្មែរនៅភូមា។

- ព្រះតេជគុណ ព្រះករុណាម្ចាស់គ្រប់អង្គនៅក្នុងសាកលវិទ្យាល័យ-ពុទ្ធសាសនទូតថេរវាទអន្តរជាតិ ដែលតែងតែជួយត្រួតពិនិត្យ និងផ្ដល់នូវមតិយោបល់ល្អៗដល់ខ្ញុំ។

សូមបុណ្យកុសលជាអំពើល្អតាមជួយថែរក្សាអស់លោកអ្នក សប្បុរសជនគ្រប់ទិនទិវារាត្រីកុំបីខានឡើយ។ សូមឱ្យសាសនាព្រះជិនស្រីស្ថិតនៅគ្រប់ ៥០០០ ព្រះវស្សាដោយបរិបូរណ៍។ សូមឱ្យកម្ពុជរដ្ឋសំបូរទៅដោយអ្នកប្រាជ្ញបណ្ឌិតកវី ដូចអរិយប្រទេសនានានៅក្នុងសាកលលោក។

សូមអរព្រះគុណ! សូមអរគុណ!



# សេចក្ដីផ្ដើម

ជារឿយៗណាស់ ព្រឹត្តិការណ៍សប្បាយរីករាយដូចជាការកើតនិងពិធីរៀបអាពាហ៍ពិពាហ៍ និងព្រឹត្តិការណ៍មានទុក្ខព្រួយ ដូចជាការមានជម្ងឺនិងការស្លាប់ នៅក្នុងការកើតមកជាមនុស្សរបស់បុគ្គលម្នាក់ តម្រូវឱ្យប្រារព្ធធ្វើពិធីបុណ្យជាក់ស្ដែងមួយ ដែលបានប្រារព្ធធ្វើនៅគ្រប់សង្គមទាំងអស់តាំងពីបរមបូរាណមក។ ពិធីបែបនេះ ដែលបានកើតមានជាយូរលង់មកហើយមុនសាសនាធំៗផ្សេងៗគ្នារបស់ពិភពលោក បានបង្កើតឡើងនិងបន្សល់ទុកនៅរហូតដល់បច្ចុប្បន្ននេះដោយដូនតារបស់យើង ហើយឆ្លងកាត់មួយអំឡុងពេលមក បានទទួលយកទម្រង់ នៃការប្រតិបត្តិតាមប្រពៃណីទំនៀមទម្លាប់ ជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ននេះ។ យើងបន្តប្រារព្ធធ្វើភាគច្រើននៃពិធីទាំងនេះ តាមរយៈការភ័យខ្លាច និងដោយងងឹតងងល់ មិនហ៊ានផ្លាស់ប្ដូរ ឬបោះបង់ចោលពិធីទាំងនោះ ទោះបីជាមានគ្រឿងឧបទេសអប់រំសម័យទំនើប និងបែបផែនជីវិតជឿនលឿនក៏ដោយ។

នៅក្នុងពិធីបុណ្យភាគច្រើន ដែលប្រារព្ធធ្វើនៅក្នុងពិធីទុក្ខព្រួយ ដូចជាការស្លាប់និងពិធីបុណ្យសព គ្របដណ្ដប់និងលាក់ទុកនូវអាថិកំបាំងនិងជំនឿឆ្វេង និងជារឿយៗបង្កជាបន្ទុកហិរញ្ញវត្ថុធំសម្បើមលើគ្រួសារសព។ នេះជាហេតុផលមួយក្នុងចំណោមហេតុផលចំបងៗ ដែលពុទ្ធសាសនិកជាច្រើននាក់

ងាយនឹងគេអូសទាញឱ្យផ្លាស់ប្តូរសាសនាទៅចូលសាសនាដទៃ ពីព្រោះវាផ្តល់នូវគ្រាប់រំសេវដ៏ល្អសម្រាប់អ្នកកាន់សាសនាដទៃ ឱ្យបោះសំដីរិះគន់យ៉ាងខ្លាំង និងវាយប្រហារមកលើអ្នកកាន់ព្រះពុទ្ធសាសនា។ វាជាការចាំបាច់ ដែលសហគមពុទ្ធសាសនានៅក្នុងប្រទេសនេះ គួរតែភ្ញាក់ឡើងចំពោះស្ថានភាពនេះ និងប្រឹងប្រែងលើកទឹកចិត្ត ដើម្បីធ្វើការកែប្រែការប្រារព្ធធ្វើពិធីបុណ្យទាំងនេះក្នុងភាពចុះសម្រុងគ្នា ជាមួយគោលសាសនាត្រឹមត្រូវបែបព្រះពុទ្ធសាសនា។

សៀវភៅនេះបង្ហាញងាយៗ និងអាចយល់បាននូវពិធីបុណ្យបែបសាសនាផ្សេងៗគ្នា ដែលអាចត្រូវបានប្រារព្ធធ្វើដោយពុទ្ធសាសនិកក្នុងព្រឹត្តិការណ៍សប្បាយរីករាយ និងទុក្ខព្រួយនៅក្នុងជីវិតរស់នៅរបស់ពួកគេ។ ខ្ញុំសង្ឃឹមថាពួកគេនឹងខិតខំប្រឹងប្រែងស្វែងយល់ និងប្រារព្ធធ្វើពិធីទាំងនោះ នៅពេលព្រឹត្តិការណ៍នោះកើតមានឡើង។ ដោយធ្វើបែបនេះ ពួកគេនឹងមិនត្រឹមតែទទួលបាននូវភាពពេញចិត្ត និងសុវត្ថិភាពក្នុងចំណេះដឹងដែលពួកគេប្រារព្ធធ្វើពិធីបុណ្យបែបព្រះពុទ្ធសាសនាត្រឹមត្រូវសមរម្យប៉ុណ្ណោះទេ ថែមទាំងជួយថែរក្សារូបភាពនៃសាសនាផ្ទាល់របស់ពួកគេ នៅក្នុងកែវភ្នែកអ្នកដទៃទៀតផង។

**តាន តេកម៉េង**

ប្រធានសមាគមពុទ្ធសាសនទូតម៉ាឡេស៊ី

១ មករា ១៩៨៩

# មាគ៌ាព្រះពុទ្ធសាសនា

## ភាតព្វកិច្ចមាតាបិតាក្នុងការអប់រំបុត្រធីតា

ការប្រសូត្របុត្រគឺជាព្រឹត្តិការណ៍គួរឱ្យសប្បាយរីករាយ។ ការមានបុត្រធីតានិងការអប់រំពួកគេ គឺជាការផ្សងព្រេងដែលអាចត្រូវបានចាប់ផ្តើមយ៉ាងសប្បាយរីករាយនិងមានទំនុកចិត្ត។ ទន្ទឹមនឹងនេះដែរ វាមានន័យថាជាការចាប់ផ្តើមអំឡុងពេលមួយដ៏វែងឆ្ងាយ នៃការធ្វើពលិកម្មនិងទំនួលខុសត្រូវសម្រាប់មាតាបិតា។ ទោះបីជាសត្វលោកធ្វើដំណើរវែងឆ្ងាយរុលទៅមុខលើកាំជណ្តើរដែលចម្រើនផ្លាស់ប្តូរយុវវ័យរបស់គេ ជាធម្មជាតិ ប្រើពេលវេលាដ៏វែងឆ្ងាយមួយ ដើម្បីពេញវ័យឡើងនិងក្លាយជាឯករាជ្យ។ មាតាបិតាមានកាតព្វកិច្ចមួយទ្រាំទ្របំពេញទំនួលខុសត្រូវថែទាំបុត្រធីតារបស់ពួកគាត់ និងចិញ្ចឹមអប់រំបុត្រធីតាទាំងនោះ ឱ្យក្លាយជាយុវជនមានប្រយោជន៏សម្រាប់ថ្ងៃអនាគត។ ទោះបីជាយ៉ាងណាក៏ដោយ អស់រយៈពេលជាច្រើនសតវត្សរ៏មកសង្គមទាំងឡាយ បានអភិវឌ្ឍរូបមន្តដែលបានសាកល្បងទទួលបានលទ្ធផលល្អដើម្បីណែនាំមាតាបិតានៅក្នុងភារកិច្ចចិញ្ចឹមអប់រំកូននេះ។ នៅក្នុងទំនាក់ទំនងនេះ សាសនាក៏ដើរតួនាទីកណ្តាលក្នុងការផ្តល់ឱ្យមាតាបិតានូវគម្រោងមួយនៅក្នុងនោះ ដើម្បីបង្ហាត់បង្រៀនយុវជននូវក្រមសីលធម៌ អាកប្បកិរិយា និង



សីលធម៌។ នៅក្នុងព្រះពុទ្ធសាសនា ព្រះពុទ្ធទ្រង់ធ្លាប់បានផ្តល់នូវឱវាទមានប្រយោជន៏សំខាន់ណាស់ ស្តីអំពីកាតព្វកិច្ចមាតាបិតាចំពោះបុត្រធីតា និងកាតព្វកិច្ចបុត្រធីតាចំពោះមាតាបិតាផងដែរ។ **សិង្គាលោវាទសូត្រ** គឺជាព្រះសូត្រ ដែលបានផ្តល់នូវកាតព្វកិច្ចដ៏មានតម្លៃ។ ព្រះពុទ្ធទ្រង់បានសម្តែងនិទានឧប្បត្តិហេតុមួយ ដែលព្រះអង្គសម័យមួយបានកត់សម្គាល់បុរសម្នាក់ប្រារព្ធធ្វើពិធីបែបសាសនាសាមញ្ញមួយ ដោយគោរពទិសទាំងប្រាំមួយ (ទិសខាងជើង, ខាងត្បូង, ខាងកើត, ខាងលិច, ខាងលើ និងទិសខាងក្រោម)។ នៅពេលដែលព្រះអង្គសាកសួរពីអត្ថន័យនិងគោលបំណងនៃសកម្មភាពរបស់គាត់ បុរសនោះក៏បានតបព្រះពុទ្ធដីកាថា គាត់មិនបានដឹងពីអត្ថន័យនៃការប្រារព្ធធ្វើរបស់គាត់នោះទេ ប៉ុន្តែថាគាត់ធ្វើតាមបណ្តាំរបស់បិតាគាត់ពេលហៀបនឹងស្លាប់។ ជាការពិតជាក់ស្តែង ព្រះពុទ្ធទ្រង់មិនបានស្តីបន្ទោសបុរសនោះ ដែលបានធ្វើនូវពិធីសាសនាបែបនេះទេ ថែមទាំងបានផ្តល់នូវអត្ថន័យមានសារៈសំខាន់ដោយការប្រតិបត្តិ។ ព្រះអង្គបានសម្តែងថា ការគោរពទិសទាំងប្រាំមួយជានិមិត្តរូបដែលផ្តល់កិត្តិយស និងបំពេញករណីកិច្ចនិងកាតព្វកិច្ចរបស់ខ្លួនចំពោះមាតា-បិតា គ្រូអាចារ្យ អ្នកបួស បុត្រភរិយា និងអ្នកនៅក្រោមបង្គាប់របស់ខ្លួន។ ហេតុដូច្នេះ យើងឃើញថា ព្រះសម្មាសម្ពុទ្ធទ្រង់បានសង្កត់យ៉ាងធ្ងន់ទៅលើទំនាក់ទំនងរបស់បុគ្គលម្នាក់ជាមួយអ្នកដទៃ ប៉ុន្តែពិសេសជាងនេះទៅទៀត

រវាងមាតាបិតានិងបុត្រធីតា។ មាតាបិតាត្រូវថែទាំបុត្រធីតា ដោយផ្តល់ឱ្យពួកគេនូវឯករាជ្យភាពក្នុងកាលដ៏សមគួរ និងផ្តល់ឱ្យពួកគេនូវកេរ្តិ៍មតិកសមរម្យក្នុងសម័យដ៏គួរ។ ម្យ៉ាងទៀតបុត្រធីតាត្រូវបំពេញកាតព្វកិច្ចថែទាំមាតាបិតាដោយផ្តល់ឱ្យពួកគាត់នូវភក្តីភាពជាកូន។ កាតព្វកិច្ចនេះត្រូវធ្វើ ក្រៅពីការគោរព និងកតញ្ញូតាធម៌ទៅវិញទៅមកចំពោះពួកគាត់ និងមិនត្រូវរំពឹងការធ្វើតបពីពួកគាត់វិញទេ។ កត់សម្គាល់ឃើញថា មានការតភ្ជាប់ជិតស្និទ្ធរវាងសាសនានិងទំនាក់ទំនងរវាងមាតាបិតានិងបុត្រធីតា។ មាតាបិតាមិនគួរមិនអើពើគួសបន្ទាត់ពីក្រោមសារៈសំខាន់ផ្នែកសាសនា អំពីការប្រសូត្របុត្រនោះទេ។ គ្រួសារដែលអភិវឌ្ឍទំនាក់ទំនងតាមបន្ទាត់សាសនា ដែលបានបង្កើតឡើងយ៉ាងមានសុភវិនិច្ឆ័យ មិនអាចធ្វើឱ្យរំលងខកខានបានឡើយ។

មាតាបិតាមានកាតព្វកិច្ចអភិវឌ្ឍទំនាក់ទំនងបែបនេះ ដោយផ្អែកលើកេរ្តិ៍ដំណែលវប្បធម៌សាសនារបស់ពួកគេ។ ទន្ទឹមនឹងអ្នកកាន់សាសនាដទៃទៀតមានពិធីការនិងកាតព្វកិច្ចធ្វើពិធីលាងបាបនិងដាក់នាមតាមបែបសាសនា មាតាបិតាកាន់ព្រះពុទ្ធសាសនា ត្រូវការត្រឹមតែនាំបុត្រធីតារបស់ពួកគេទៅវត្តអារាមដើម្បីបញ្ជាក់ឡើងវិញនូវជំនឿរបស់ពួកគេក្នុងព្រះរតនត្រៃយ៍ និងទទួលត្រៃសរណគមន៍ យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹក។ ដោយដល់នូវព្រះរតនត្រៃយ៍ជាទីពឹងទីរលឹក មាតាបិតាអាចមានជំនឿទុកចិត្ត



ក្នុងការចិញ្ចឹមបីបាច់អប់រំបុត្រធីតារបស់ពួកគាត់ មានការធានាយ៉ាងមុតមាំថាបុត្រធីតា ត្រូវបានការពាររារាំងបញ្ចៀសពីឧបទ្រព្យចង្រៃទាំងពួង។ យើងមិនអាចបដិសេធការកើតមានឧបទ្រព្យចង្រៃនៅជុំវិញយើង ដែលព្យាបាទសត្វ និងដែលអាចបង្កឱ្យមានគ្រោះកាចចង្រៃ។ ការនាំបុត្រធីតាទៅកាន់វត្តអារាម និងការទទួលបាននូវពិធីកម្មសាសនាជាប្រពៃណី ពិតជាអាចផ្តល់នូវសុខុមាល-ភាពដល់បុត្រធីតា។ គេក៏អាចចាត់ទុកថាជាជំហានដំបូងក្នុងការភ្ជាប់ទំនាក់ទំនងបុត្រធីតាជាមួយនឹងវត្តអារាម ដែលប្រសិនបើបានបន្តពីវ័យនៅក្មេង និងអាចក្លាយជាមួយភាគនៃជីវិត។ ទម្លាប់នេះ បើរក្សារហូតដល់ជីវិតវ័យជំទង់ អាចផ្តល់ឱ្យបុគ្គលនូវជំហររឹងប៉ឹងល្អ នៅពេលប្រឈមមុខជាមួយបញ្ហា។



សាសនាជួយក្មេងៗឱ្យដើរតាមផ្លូវត្រូវ

# ពិធីមង្គលសម្រាប់បុត្រធីតា

ការសូត្រព្រះសូត្រទាំងឡាយ ផ្តល់ផលជាគុណប្រយោជន៍ដល់បុត្រធីតា។ នៅក្នុងសម័យពុទ្ធកាល នៅពេលកុមារម្នាក់ ដែលស្ថិតនៅក្នុងគ្រោះថ្នាក់ ដោយសារពពួកអសុរកាយ ត្រូវបានគេយកមកទុកមុខព្រះភ័ក្ត្រព្រះដ៏



ព្រះពុទ្ធទ្រង់សង្គ្រោះជីវិតរបស់កុមារម្នាក់



មានព្រះភាគៗ បានសម្តែងថាព្រះសូត្រគឺត្រូវសូត្រដោយព្រះសង្ឃ (គណៈ-សង្ឃ)។ ផលជាលទ្ធផល គឺថាកុមារនោះបានបញ្ចៀសចេញពីសេចក្តីស្លាប់ ហើយបានរស់រានមានជីវិតរហូតដល់វ័យចាស់ជរា។ កុមារនោះមានឈ្មោះថា **អាយុវឌ្ឍនៈ** មានន័យថា "អាយុវែង" ពីព្រោះកុមារនោះលែងស្ថិតនៅក្នុងគ្រោះថ្នាក់អំពីសេចក្តីស្លាប់មុនកាលកំណត់។

## ហេតុអ្វីបានជាយើងសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក?

នៅពេលដែលអ្នកទាំងឡាយណាដែលជឿថា អាទិទេពបង្កើតឱ្យមានសេចក្តីភ័យខ្លាច សេចក្តីសោក ឬក៏ការរំខានណាមួយ ពួកគេបួងសួងសុំឱ្យអាទិទេពជួយការពារ។ ពុទ្ធសាសនិកជាច្រើនសួរអ្នកណាដែលពួកគេអាចពឹងពាក់បាន នៅពេលដែលពួកគេប្រឈមមុខនឹងអសុវត្ថិភាព។ នៅក្នុងកាលៈ-ទេសៈបែបនេះ ពុទ្ធសាសនិកអាចនឹកឃើញព្រះពុទ្ធឡើងវិញនៅក្នុងចិត្តរបស់គេ និងស្វែងរកការរំសាយពីទុក្ខព្រួយ។ មិនមានចម្ងល់ទេ ដែលបញ្ញត្តិពុទ្ធសាសនាអំពីអាទិទេព ខុសពីបញ្ញត្តិនៅក្នុងសាសនាដទៃទៀត ប៉ុន្តែនៅពេលពួកគេនឹកគិតដល់គុណរបស់ព្រះពុទ្ធ ការឈ្នះមារ សេចក្តីស្ងប់ និងលក្ខណៈរបស់ព្រះអង្គ ចិត្តរបស់ពួកគេនឹងស្ងប់ ហើយពួកគេនឹងទទួលបាននូវជំនឿក្នុងចិត្ត។ ថ្វីបើអ្នកកាន់សាសនាដទៃជាច្រើននាក់និយាយថា អាទិទេពមិនមែនជាមនុស្សទេ ប៉ុន្តែជាកម្លាំងមួយដែលគេគួរសម្គាល់ឃើញមាននៅក្នុងចិត្តរបស់

ពួកគេ។ នៅពេលចិត្តរបស់ពួកគេស្ងប់និងរឹងមាំដោយផ្តោតលើកម្លាំងនេះ ពួកគេស្ថិតនៅក្នុងចំណុចមួយ ដើម្បីប្រឈមមុខឧបសគ្គរារាំង ដើម្បីវាយតម្លៃបញ្ហា និងរកមធ្យោបាយដើម្បីយកឈ្នះលើបញ្ហាទាំងនោះ។ ពុទ្ធសាសនិកអាចយកឈ្នះលើបញ្ហារបស់ពួកគេ ដោយវិធីស្រដៀងគ្នាដែរ ដោយនឹកដល់ព្រះពុទ្ធ។ ជាធម្មតា ភាគច្រើននៃបញ្ហារបស់យើង គឺបង្កឡើងដោយចិត្ត ហើយចិត្តតែមួយក៏អាចដោះស្រាយបញ្ហាទាំងនោះបាន តាមរយៈការយល់ដឹង និងជំនឿជឿជាក់។ នេះជាមូលហេតុ ដែលចំណេះចេះដឹងព្រះធម៌មានសារៈសំខាន់។ នៅពេលដែលចិត្ត ត្រូវពង្រឹងឱ្យរឹងប៉ឹង តាមរយៈការញ៉ាំងចិត្ត និងភក្តិភាពចំពោះព្រះពុទ្ធ វាអាចយកឈ្នះលើសភាពចិត្តដែលគ្មានអ្នកណាអាចជួយបាន និងសេចក្តីភ័យខ្លាចអសុរកាយ ការទុកឱ្យនៅម្នាក់ឯង និងទទួលបានមកវិញនូវជំនឿជឿជាក់។ នេះគឺជាអត្ថន័យ ថាហេតុអ្វីបានជាយើងសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក។

ទន្ទឹមនឹងការរកទីពឹងទីរលឹកឱ្យបុត្រធីតានៅវត្តអារាម ការបូជាផ្កា ធូប ទៀន និងផ្លែឈើអាចធ្វើនៅកន្លែងសក្ការបូជា ហើយព្រះសង្ឃគង់នៅទីនោះនិមន្តសូត្រស្វាធ្យាយព្រះសូត្រទាំងឡាយ ដើម្បីប្រោះព្រំជ័យមង្គលដល់បុត្រធីតានោះ។ ប្រសិនបើមានបំណងចង់បាន គេក៏អាចសុំព្រះសង្ឃឱ្យដាក់ឈ្មោះសមរម្យបែបព្រះពុទ្ធសាសនាដល់បុត្រធីតានោះទៀតផង។



នៅពេលដែលកុមារចម្រើនវ័យធំធាត់ឡើង វាជាទំនួលខុសត្រូវរបស់មាតាបិតានាំបុត្រធីតាទៅកាន់វត្តអារាមយ៉ាងទៀងទាត់ ដើម្បីអាចចូលរួមជាមួយមនុស្សម្នាដែលមានចិត្តគំនិតសាសនា ហើយនិងស្តាប់ការសន្ទនាតាមបែបសាសនាសាមញ្ញៗ និងស្តាប់ព្រះធម៌ព្រមទាំងទាញយកផលប្រយោជន៍ពីការស្តាប់នោះ។ ឆ្លងកាត់អស់មួយរយៈមក បុត្រធីតាស៊ាំប្រតិបត្តិតាមព្រះពុទ្ធសាសនា ហើយនឹងមានអារម្មណ៍សុខស្រួលនៅក្នុងចំណោមមនុស្សជុំវិញក្នុងបរិយាកាសស្ងប់ស្ងៀមនៅក្នុងវត្តអារាម។ ពិតណាស់ គេគួរតែនាំកុមារទៅវត្តអារាមផងដែរ ដើម្បីធ្វើពិធីកម្មក្នុងព្រះពុទ្ធសាសនា នៅក្នុងឱកាសសំខាន់ៗ ដូចជា ថ្ងៃដំបូងដែលពួកគេទៅសាលារៀន ថ្ងៃប្រឡង ថ្ងៃបុណ្យខួបកំណើត និងព្រឹត្តិការណ៍គួរឱ្យសប្បាយរីករាយដទៃទៀត។ នៅពេលកុមារធ្លាប់ស្តាប់ព្រះសូត្រ ពួកគេទទួលបាននូវទំនុកចិត្តធំមហិមាក្នុងខ្លួនរបស់ពួកគេ ពីព្រោះពួកគេបានដឹង តាមរយៈឥទ្ធិពលមានគុណប្រយោជន៍របស់ព្រះសូត្រ ពួកគេកំពុងមានអ្វីមកជួយការពារ។ ហេតុនេះ ពួកគេមានទំនោរធ្វើអ្វីដែលពួកគេព្យាយាមធ្វើកាន់តែប្រសើរឡើង ហើយជាលទ្ធផលគឺមិនមានអារម្មណ៍ព្រួយបារម្ភនិងភ័យខ្លាច មានអារម្មណ៍ផុតពីគ្រោះថ្នាក់កាន់តែច្រើន ហើយនឹងលែងមានការភ័យខ្លាច ឬញញើតខ្លាំងពីការទុកឱ្យនៅអស់សង្ឃឹម។



គ្រួសារពុទ្ធសាសនិកគប្បីរស់នៅក្នុងពន្លឺរបស់ព្រះពុទ្ធ



## ការអប់រំបែបព្រះពុទ្ធសាសនា និងការប្រតិបត្តិតាមវប្បធម៌

វិធីមានប្រសិទ្ធិភាពក្នុងការណែនាំបង្រៀនមេរៀនសាសនាដល់ក្មេងៗ ស្តីពីសីលធម៌ និងក្រមសីលធម៌ សុជីវធម៌ គឺធ្វើតាមរយៈរូបភាព រូបភាពសម្រាប់ពន្យល់ និមិត្តរូបសាសនា និងតាមរយៈការជជែកគួរឱ្យចាប់អារម្មណ៍ ស្តីពីរឿងនិទាននិងជាតកព្រះពុទ្ធសាសនា។ វិធីសាស្ត្រនេះ អាចនិយាយប្រាប់មនុស្សជាច្រើននាក់ ជាពិសេសក្មេងៗ ហើយវាអាចជួយពួកគេឱ្យតម្លៃលើព្រះពុទ្ធសាសនាកាន់តែខ្លាំងឡើង។ ការនិយាយប្រាប់ពីដំណើររឿង ឬឆាកណាមួយដែលពណ៌នាព្រឹត្តិការណ៍និទានជាតកពុទ្ធសាសនាជាប្រវត្តិសាស្ត្រ ក៏អាចជួយបង្កើតការចាប់អារម្មណ៍ល្អ និងមានរយៈពេលវែងលើចិត្តគំនិតក្មេងៗ។

ដើម្បីដឹកនាំបុត្រធីតាឱ្យដើរផ្លូវត្រូវ មាតាបិតាផ្ទាល់ដំបូងគួរធ្វើជាគំរូ និងដឹកនាំជីវិតប្រកបដោយឧត្តមគតិ។ វាមិនអាចរំពឹងថាបានកូនមានគុណប្រយោជន៍ គុណសម្បត្តិចេញពីមាតាបិតាដែលគ្មានគុណប្រយោជន៍នោះទេ។ ក្រៅពីទំនោរកម្មផល បុត្រធីតាក៏ទទួលឥទ្ធិពលពីភាពមានខ្ចោះនិងគុណធម៌របស់ឪពុកម្តាយផងដែរ។ មាតាបិតាដែលមានការទទួលខុសត្រូវ គួរតែប្រុងប្រយ័ត្នកុំបញ្ជូនលក្ខណៈអវិជ្ជមានទៅឱ្យបុត្រធីតារបស់ខ្លួន។

ព្រះពុទ្ធទ្រង់ប្រៀនប្រដៅថា យើងមិនគួរទទួល ឬបដិសេធចោលប្រពៃណីនិងទំនៀមទម្លាប់ណាមួយ ដោយគ្មានការគិតពិចារណាមុនដំបូង

ទោះបីប្រពៃណីនិងទំនៀមទម្លាប់បែបនោះ មានអត្ថន័យ និងអត្ថប្រយោជន៍ក៏ដោយ។ គេមិនសូវសង្កត់ធ្ងន់ទៅលើវិធីទាំងនេះ នៅពេលដែលគេបានរៀនព្រះធម៌ ដើម្បីដឹកនាំជីវិតឱ្យមានន័យតាមបែបព្រះពុទ្ធសាសនា។ ព្រះពុទ្ធទ្រង់




មាតាបិតាគប្បីបង្រៀនបុត្រធីតាឱ្យក្លាយជាពុទ្ធសាសនិកដ៏ល្អ



សម្ដែងថា ទោះបីយើងប្រើប្រាស់វិធីឬមធ្យោបាយអ្វីក៏ដោយ ដើម្បីហ្វឹកហាត់ចិត្តរបស់យើង អាកប្បកិរិយារបស់យើងគួរធ្វើឱ្យដូចបុរសម្នាក់ឆ្លងកាត់ទន្លេដោយក្បូន។ បន្ទាប់ពីឆ្លងទន្លេរួច បុរសនោះមិនជាប់ចិត្តនិងក្បូននោះទេ គាត់បានទុកវាចោលនៅច្រាំងមាត់ទន្លេ ដើម្បីបន្តដំណើរទៅមុខទៀត។ ដូចគ្នានេះដែរ ការធ្វើតាមវប្បធម៌ប្រពៃណី គេគួរចាត់ទុកគ្រាន់តែជាជំនួយ ដើម្បីទទួលបានការជំរុញទឹកចិត្ត និងមិនគួរចាត់ទុកថាជាទីបញ្ចប់របស់ខ្លួនគេនោះទេ។

ការគោរពតាមវប្បធម៌ប្រពៃណីតាមបែបព្រះពុទ្ធសាសនា ផ្សេងគ្នាពីប្រទេសមួយទៅប្រទេសមួយ។ នៅពេលប្រារព្ធធ្វើពិធីតាមបែបប្រពៃណីទាំងនេះ យើងគួរតែប្រុងប្រយ័ត្ន មិនត្រូវចាត់ថ្នាក់ព្រះពុទ្ធសាសនាចូលទៅក្នុងប្រពៃណីណាមួយក្នុងចំណោមប្រពៃណីទាំងនោះៗទេ។ ជាតួយ៉ាង យើងមិនគួរគិតថា ព្រះពុទ្ធសាសនាចិន ព្រះពុទ្ធសាសនាសេរីលង្កា ព្រះពុទ្ធសាសនា-ជប៉ុន ព្រះពុទ្ធសាសនាថៃ ព្រះពុទ្ធសាសនាភូមា ឬព្រះពុទ្ធសាសនាទីបេទេ។ នេះគ្រាន់តែបង្កើតឱ្យមានការមិនឯកភាពគ្នា ការរើសអើង និងការយល់ច្រឡំ។ យើងគួរតែស្វែងយល់ផងដែរ អំពីមេដឹកនាំព្រះពុទ្ធសាសនាស៊ីគេនោះ ដែលជាអ្នកព្យាយាមធ្វើឱ្យស្លាកព្រះពុទ្ធសាសនារបស់គេមាំទាំ ដោយបញ្ចូលទម្រង់ជាច្រើននៃមន្តអាគម កម្លាំងអំណាចអាទិទេព អំណាចអភិធម្មជាតិ និងបញ្ញត្តិដើម្បីបោកបញ្ឆោតជនដ៏ច្រើន។ អំពើគ្មានសីលធម៌បែបនេះធ្វើឡើងជា

មួយការទាត់ចោលទាំងស្រុងទៅនឹងអ្វីដែលព្រះពុទ្ធទ្រង់បានសម្តែង អំពីការប្រតិបត្តិបែបនេះ។

ការប្រារព្ធពិធីសាមញ្ញមួយទៀតរបស់អ្នកកាន់ព្រះពុទ្ធសាសនា គឺការប្រារព្ធធ្វើពិធីបុណ្យសូត្រមន្តឡើងផ្ទះ។ នៅពេលណាដែលគេផ្លាស់ទៅនៅក្នុងទីលំនៅគេហដ្ឋានថ្មី ឬនៅពេលដែលប្តូរទីកន្លែងពីតំបន់មួយទៅតំបន់មួយទៀត ជាប្រពៃណីទំនៀមទម្លាប់ទូទៅរបស់ពុទ្ធសាសនិកនិមន្តព្រះសង្ឃប្រារព្ធធ្វើពិធីសូត្រមន្តឡើងផ្ទះ គឺដើម្បីធានាថាទីកន្លែងត្រូវបានរារាំងការពារ តាមអារម្មណ៍ផ្លូវចិត្ត ក៏ដូចជាឱ្យបានជាទីលំនៅសុខសាន្តសម្រាប់អ្នកទាំងអស់ដែលនៅក្នុងគេហដ្ឋាន និងដើម្បីឱ្យសុភមង្គល សុខសន្តិភាព និងជយមង្គលជ្រួតជ្រាបនៅពេញផ្ទះថ្មី។ ដូចគ្នានេះដែរ គេក៏ប្រារព្ធធ្វើពិធីឡើងគេហដ្ឋានថ្មី នៅពេលបើកអគារជំនួញថ្មី ឬនៅពេលណាដែលបើកមុខជំនួញថ្មីៗ។

## ពិធីអាពាហ៍ពិពាហ៍

បើតាមព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា នៅពេលបុត្រធីតាចម្រើនវ័យវឌ្ឍនាការចូលដល់យុវវ័យ គឺជាកាតព្វកិច្ចរបស់មាតាបិតា ស្វែងរកគូស្រករសមរម្យឱ្យបុត្រធីតា។ ជាការពិត នេះមិនមែនទំនៀមទម្លាប់សម័យបច្ចុប្បន្ននៅក្នុងសង្គមទំនើប ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ មាតាបិតាអាចគាំទ្រ នៅពេលដែលបុត្រធីតារបស់ពួកគេ ចាប់ផ្តើមស្វែងរកដៃគូសម្រាប់ខ្លួនគេផ្ទាល់។



នេះគួរតែជាឱកាសល្អបំផុតដើម្បីជួយពួកគេ មិនត្រឹមតែផ្អែកសម្ភារៈទេ ថែមទាំងផ្តល់ដំបូន្មាននិងការណែនាំមិនសម្លេង នៅក្នុងជម្រើសដៃគូសមរម្យ ដើម្បីចៀសវាងរណ្តៅនៅក្នុងជីវិត។ ប្រសិនបើបុត្រធីតាបានមកវត្តអារាមទៀង



អាពាហ៍ពិពាហ៍គប្បីរៀបចំនៅក្នុងបរិយាកាសបែបសាសនា

ទាត់ ឱកាសទាំងឡាយគឺថាពួកគេអាចមានឱកាសចូលរួមជាមួយយុវជនអ្នកកាន់ព្រះពុទ្ធសាសនាដទៃទៀត ដែលចែករំលែកជាមួយពួកគេនូវតម្លៃនិងអត្ថប្រយោជន៍សាសនាដូចគ្នា និងជាអ្នកអាចរៀបអាពាហ៍ពិពាហ៍ជាមួយដៃគូល្អ។

គេកត់សម្គាល់ឃើញថា ពុទ្ធសាសនិកជាច្រើននៅក្នុងប្រទេសនេះ ទំនងជាភ្លេចករណីកិច្ចផ្នែកផ្លូវចិត្តរបស់ពួកគេ នៅពេលឱកាសសំខាន់បំផុតនិងអធិកអធមក្នុងជីវិតរបស់ពួកគេ ពោលគឺអាពាហ៍ពិពាហ៍របស់ពួកគេ។ វាជាប្រពៃណីនៅក្នុងបណ្ដាប្រទេសកាន់ព្រះពុទ្ធសាសនា ក្នុងពិធីរៀបអាពាហ៍ពិ-ពាហ៍ និមន្តព្រះសង្ឃទៅកាន់គេហដ្ឋាន ដើម្បីជាជយមង្គល។ នេះអាចប្រារព្ធធ្វើទាំងមុននិងក្រោយពិធីអាពាហ៍ពិពាហ៍ ជាធម្មតាប្រារព្ធធ្វើនៅគេហដ្ឋាន។ គេសង្ឃឹមថា គូស្រករជាអ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់ បានបំពេញករណីកិច្ចរបស់ពួកគេក្នុងអាការៈបែបនេះ ពេលពួកគេរៀបអាពាហ៍ពិពាហ៍។ ការប្រគេនផ្កាភ្ញី ធូប ទៀន ទាំងអស់នេះសុទ្ធតែចាំបាច់ត្រូវឱ្យមានក្នុងពិធីសូត្រមន្ត ដែលឪពុកម្ដាយទាំងសងខាង និងសាច់សារលោហិតព្រមទាំងមិត្រភ័ក្តិអាចអញ្ជើញឱ្យចូលរួមផងដែរ។ ពិធីជយមង្គលបែបនេះ ដែលប្រាព្ធធ្វើនៅថ្ងៃនក្ខត្តឫក្ស ជាការរួមចំណែកផ្លូវចិត្តជាក់ច្បាស់ ដើម្បីទទួលបានជ័យជំនះ



សេចក្ដីសុខសាន្ត និងសុភមង្គលសម្រាប់គូស្រករដែលទើបរៀបអាពាហ៍ពិពាហ៍ហើយថ្មីៗ។

ការរំភើបភ្ញាក់ផ្អើលខ្លាំងតែម៉្យាង មិនមែនជាមូលដ្ឋានគ្រប់គ្រាន់ដើម្បីទទួលបានអាពាហ៍ពិពាហ៍ជោគជ័យនោះទេ ដូច្នេះគេគួរផ្ដល់ដំបូន្មានល្អៗដល់យុវជនក្មេងៗ ដើម្បីឱ្យដឹងច្បាស់ថាមានជ្រុងនៃផ្លូវចិត្តរបស់កិច្ចការរបស់ពួកគេ មុននឹងធ្វើសច្ចាប្រណិធានចុងក្រោយ។ នៅពេលគូស្រករចាប់ផ្ដើមអាពាហ៍ពិពាហ៍ ដោយរក្សាគោលប្រតិបត្តិផ្នែកសាសនា ពួកគេហាក់ដូចជាមានការគោរពស្ថាប័នអាពាហ៍ពិពាហ៍កាន់តែខ្លាំងឡើង ហើយពួកគេជាធម្មតាងាកមករកសាសនា ពេលមានភាពស្មុគស្មាញ ដើម្បីឱ្យបានរំសាយពីទុក្ខព្រួយ។ បន្ទាប់ពីមានអាពាហ៍ពិពាហ៍ប្រកបដោយសុភមង្គល គូស្រករមានវ័យនៅក្មេង គួរតែខិតខំធ្វើខ្លួនឱ្យទៅជាឪពុកម្ដាយ ជាអ្នកកាន់ព្រះពុទ្ធសាសនាដ៏ល្អ និងមានទំនួលខុសត្រូវចំពោះបុត្រធីតានៅថ្ងៃអនាគត។

## ពិធីបុណ្យសាសនា

ទោះបីពិធីបុណ្យ និងពិធីបុណ្យសាសនាមិនទទួលការនិយមចូលចិត្តពីបញ្ញាវន្ត ក៏យ៉ាងហោចណាស់ ការប្រារព្ធពិធីបែបនេះមានសារៈសំខាន់ ដើម្បីអភិវឌ្ឍនិងរក្សាទិដ្ឋភាពភក្ដីភាពចំពោះសាសនា និងដើម្បីបង្កើតស្មារតីជំរុញទឹកចិត្តជនដ៏ច្រើន។ ចំពោះមនុស្សជាច្រើន ការបណ្ដុះភក្ដីភាព គឺជំហានសំខាន់

ទីមួយ ឆ្ពោះទៅកាន់បទពិសោធន៍នៃសាសនា។ បើគ្មានរូបភាពភក្តីភាពនិងវប្បធម៌ ដែលភ្ជាប់ទៅនឹងព្រះពុទ្ធសាសនាទេ ពួកគេអាចលង់ទៅក្នុងជំនឿនិងការគោរពដទៃទៀតមួយចំនួន ទោះបីជាពួកគេបានដឹងច្បាស់ថា ការគោរពបែបនោះ ឈានចូលទៅក្នុងជំនឿឆ្វេង ឬជំនឿងងឹតងងល់។



និមិត្តរូបសាសនាជួយដល់ការគោរពបូជា



ជាការចាំបាច់ណាស់ សម្រាប់បណ្ដាសាសនាទាំងឡាយត្រូវមានពិធីបុណ្យសាសនាគ្មានការបង្ខិតបង្ខំ និងការគោរពបូជាសមហេតុសមផលសម្រាប់មនុស្ស ដើម្បីឱ្យពួកគេបង្ហាញនូវភក្តីភាពនិងអារម្មណ៍ផ្លូវចិត្តរបស់ពួកគេ។ ភាគច្រើននៃពិធីខាងព្រះពុទ្ធសាសនា ជួយបណ្តុះឱ្យមានទម្លាប់ល្អនិងអារម្មណ៍វិជ្ជមានដល់សាសនិកទាំងឡាយ ដែលជាលទ្ធផលក្លាយជាចេះអត់ឱនត្រាប្រណី ចេះគិតគូរដល់អ្នកដទៃ និងជាមនុស្សមានវប្បធម៌។ ជាមួយនឹងបញ្ញានិងអប្បមាទៈ (សេចក្ដីមិនប្រមាទ) ការគោរពប្រតិបត្តិបែបប្រពៃណីទាំងនេះហាក់ដូចជាពង្រឹងជំនឿរបស់ខ្លួន ដោយផ្ទុយពីផ្លូវបញ្ញាវន្តទាំងស្រុង។ ព្រះពុទ្ធសាសនា បើគ្មានភក្តីភាពទេ អាចសោះកក្រោះដាច់តែឯង និងពុំទាក់ទងនឹងការប្រតិបត្តិ។

## ប្រពៃណី ឬសាសនាដែលហាមប៉ះពាល់

ជាតិសាសន៍ភាគច្រើន មានប្រពៃណីឬសាសនាដែលហាមប៉ះពាល់ផ្ទាល់ខ្លួន។ នៅក្នុងប្រទេសម៉ាឡេស៊ី យើងប្រហែលជាមានច្រើនជាងមួយ ពីព្រោះក្រុមជនជាតិភាគតិចសំខាន់ៗបី មានជំនឿព្រលឹងនិយមផ្ទាល់ខ្លួន ហើយជំនឿនីមួយៗទទួលឥទ្ធិពលពីជំនឿដទៃៗទៀត។ ដោយសារអវិជ្ជា សេចក្ដីភ័យខ្លាច និងជំនឿឆ្វេង ក្រុមនីមួយៗមានទំនោរទទួលយកជំនឿនៃក្រុមដទៃទៀត ជាជាងសិក្សាជំនឿទាំងនោះប្រកបដោយហេតុផល ហើយចោទជំនឿ

ទាំងនោះថាមិនទាក់ទងនឹងសម័យទំនើប។ ជាតួយ៉ាង សហគមន៍អាស៊ីភាគច្រើនមានជំនឿថា ពួកគេមិនត្រូវកាត់ក្រចកដៃទេបន្ទាប់ពីថ្ងៃលិច និងមិនត្រូវកក់សក់របស់ពួកគេ នៅថ្ងៃបានកំណត់ទុកណាមួយនៅក្នុងសប្តាហ៍ទេ។ មនុស្សមួយចំនួនគិតថា វាជាសំណាងអាក្រក់ដែលបានឃើញអ្នកបួសកោរសក់មុនឃើញអ្វីៗផ្សេងទៀតនៅពេលព្រឹក ចំណែកឯអ្នកដទៃទៀតនឹងមិនបោសសំអាតផ្ទះសំបែងរបស់ពួកគេបន្ទាប់ពីថ្ងៃលិច។ គេថែមទាំងជឿថា មិនល្អទេយួរសាច់នៅពេលយប់ ដោយភ័យខ្លាចថាវាអាចទាក់ទាញបិសាចអសុរកាយ។ ឪពុកម្តាយខ្លះ បានទូន្មានកូនចៅឱ្យពាក់គ្រឿងអលង្កាធ្វើពីលោហធាតុ ដើម្បីការពារខ្មោចព្រាយបិសាច។ មានអ្នកខ្លះទៀតជឿថា ឆ្កែលូ និងទីទុយយំនៅពេលយប់ អាចនាំឱ្យមានឧបទ្រព្យចង្រៃ សំណាងអាក្រក់ និងថាញាក់ភ្នែកឆ្វេងគឺជាប្រផ្នូរអាក្រក់។ មនុស្សមួយចំនួនគិតថា រឿងរ៉ាវទាំងនេះជាបញ្ហាធ្ងន់ធ្ងរណាស់។ ប៉ុន្តែអ្នកទាំងឡាយណាមិនអើពើធ្វើមិនដឹង គឺអាចចៀសវាងផុតពីការភ័យខ្លាច និងការរំខានបៀតបៀន។

តើព្រះពុទ្ធសាសនាមានអាកប្បកិរិយាអ្វីខ្លះ ចំពោះជំនឿទាំងឡាយបែបនេះ? តើការគិតសមហេតុផលបញ្ចប់ និងជំនឿឆ្វេងចាប់ផ្តើមនៅកន្លែងណា? ជំនឿទាំងអស់នោះ ហាក់ដូចជាមានប្រភពចេញពីការភ័យខ្លាចរបស់យើង អំពីរឿងរ៉ាវ ឬបញ្ហាដែលយើងមិនដឹង។ ជួនកាល មានហេតុផលសម-



រម្យទទួលយកបានសម្រាប់ការរក្សាជំនឿទាំងនោះ។ ជាឧទាហរណ៍ វាពិតជាមិនគួរកាត់ក្រចកដៃរបស់ខ្លួននៅពេលយប់ ពីព្រោះគេអាចកាត់ត្រូវដាច់ដៃរបស់ខ្លួន។ ដោយសារតែពពួកអសុរកាយមានជាប់ទំនាក់ទំនង ព្រះពុទ្ធទ្រង់បានសម្តែងថា យើងបដិបត្តិមេត្តាធម៌ចំពោះសត្វលោកទាំងអស់ ទាំងអាចមើលឃើញនិងមិនអាចមើលឃើញ យើងមិនធ្វើឱ្យអ្នកមានទុក្ខទោស ដោយរស់នៅមានសុភវិនិច្ឆ័យ និងជឿលើអំណាចនៃព្រះធម៌ ឬសច្ចៈ ដែលព្រះពុទ្ធទ្រង់បានសម្តែងបរិយាយ ហើយយើងធ្វើឱ្យចម្រើនសម្មាទិដ្ឋិ ដោយសិក្សាពាក្យប្រៀនប្រដៅរបស់ព្រះអង្គ គ្មានអ្វីអាចធ្វើទុក្ខទោសដល់យើងឡើយ។ ជាថ្មីម្តងទៀត នេះមានន័យថា យើងត្រូវតែអភិវឌ្ឍភក្តីភាព និងជំនឿទំនុកចិត្តរបស់យើងចំពោះសាសនាដោយទៅវត្តអារាមឱ្យបានទៀតទាត់ និងដោយពិភាក្សាបញ្ហាមានប្រយោជន៍ជាមួយធម្មាចារ្យ ដើម្បីបង្កើនបន្ថែមចំណេះដឹងរបស់យើងអំពីព្រះធម៌។ វត្តអារាមត្រូវតែជាកន្លែងដែលគេអាចទទួលបានចំណេះដឹង និងការយល់ដឹងបន្ថែមទៀត ដើម្បីបោះបង់ចោលជំនឿឆ្វេង និងបំបាត់សេចក្តីភ័យខ្លាចជ្រុលហួសហេតុនៅក្នុងចិត្តរបស់មនុស្សស្លូតត្រង់។

## មន្តស្នេហ៍ និងអំពើអាបធ្មប់

ជាការសាមញ្ញធម្មតា នៅក្នុងសហគមន៍ប្រជាជនអាស៊ីជាច្រើន ដែលពួកគេគិតថា ពួកគេជាជនរងគ្រោះនៃអំពើអាបធ្មប់និងមន្តស្នេហ៍ នៅពេល

ណា ដែលពួកគេជួបប្រទះការមិនសប្បាយចិត្តមួយចំនួននៅក្នុងជីវិតរបស់ពួកគេ។ ការបង្ហាញប្រាប់ដ៏តិចតួចបំផុតដែលថារឿយៗ ពួកគេបែរជារត់ទៅរកអ្នកទាយហេតុការណ៍ អ្នកហោរាសាស្ត្រ គ្រូខ្មោច និងគ្រូអារក្ស។ ពិតមែនហើយ ការចិញ្ចឹមជីវិតរបស់អ្នកលក់មន្តអាគមនិងមន្តស្នេហ៍ទាំងនេះ ពឹងផ្អែកលើការប្រាប់អតិថិជនរបស់ពួកគេថា អ្វីមួយខុស ឬថាខ្មោចព្រាយបិសាចបានចូលទៅក្នុងរូបនរណាម្នាក់ បង្កើតឱ្យកើតឡើងសំណាងអាក្រក់ដល់គ្រួសាររបស់ពួកគេ។ អ៊ីចឹងហើយ គ្រូទាំងនោះប្រកាសថាអាចរារាំងខ្មោចព្រាយបិសាចបាន ហើយទារប្រាក់មួយចំនួន ដោយសន្យាថាព្យាបាលឱ្យពួកគេ។ ជារឿយៗណាស់ មិនត្រឹមតែផលគឺថាជនរងគ្រោះមិនចេះសង្ស័យទាំងនេះបញ្ចប់ត្រឹមតែអស់ប្រាក់កាសពីហោប៉ៅ ហើយជាលទ្ធផលគឺគ្មាននរណាម្នាក់បានយល់ដឹងពីបទពិសោធន៍នោះទេ។ ព្រះពុទ្ធសាសនាដែលកំពុងពេញនិយម មិនត្រូវបានចែករំលែកដោយអំពើប៉ផ្លិចប៉ផ្លូចរបស់គ្រូពេទ្យ ផ្តេសផ្តាស ក្លែងក្លាយ និងអ្នកឃោសនាអួតបញ្ឆោត អ្នកមួយចំនួនក្នុងចំណោមអ្នកទាំងនោះ ថែមទាំងបានក្លែងបន្លំខ្លួនធ្វើជាព្រះសង្ឃ ដើម្បីរកប្រាក់កាសលឿនរហ័សពីជនរងគ្រោះមិនចេះសង្ស័យ។ ប៉ុន្តែ ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសថា ភាគច្រើននៃគ្រោះកាចរបស់យើង បង្កើតឡើងជាចាំបាច់ដោយចិត្តមិនបរិសុទ្ធ មិនបានហ្វឹក



ហាត់ ហើយមានតែតាមរយៈការព្យាយាម និងការយល់ដឹងរបស់យើងផ្ទាល់ប៉ុណ្ណោះ ដែលនឹងអាចយកឈ្នះលើគ្រោះកាចទាំងនោះបាន។

នៅក្នុងប្រទេសនេះ ជាពិសេសមានជំនឿបែបនេះច្រើនសន្ធឹកសន្ធប់ណាស់។ មានច្រើនបែបនេះ ដោយសារតែជាតិសាសន៍សំខាន់ៗបីមានជំនឿចំឡែកៗផ្ទាល់ខ្លួនរបស់គេ ហើយកើតមានការផ្លាស់ប្តូរគ្នាជាច្រើនសម្បើម អ៊ីចឹងហើយ នៅប្រទេសនេះបានអភិវឌ្ឍជំនឿស្រាប់ៗផ្សេងៗយ៉ាងធំសម្បើម ដែលជារបស់ប្រជាជនម៉ាឡេស៊ីតែមួយគត់។

ការព្យាបាលគ្រោះកាចប្រភេទណាមួយរបស់ព្រះពុទ្ធសាសនា គឺមានលក្ខណៈវិទ្យាសាស្ត្រ ដូចទ្រឹស្តីវេជ្ជសាស្ត្រខាងវិកលចរិតសម័យបច្ចុប្បន្ន។ ការព្យាបាលនេះ មានសង្ខេបនៅក្នុងអរិយសច្ចៈទីពីរ (ហេតុនាំឱ្យមានសេចក្តី-ទុក្ខ)។ មុននឹងយើងអាចរកការព្យាបាលគ្រោះកាច (**សំណាងអាក្រក់ សុខ-ភាពមិនល្អ ការបាត់បង់នរណាម្នាក់ឬអ្វីមួយផ្ទាល់ខ្លួន និងបញ្ហាគ្រួសារ**) យើងត្រូវតែរកឱ្យឃើញឫសគល់របស់វា។ យើងត្រូវតែពិនិត្យ ឱ្យបានសមហេតុសមផលនូវអ្វីដែលកំពុងកើតឡើងដោយពិត និងយល់ដឹងថា មានតែយើងម្នាក់ឯងគត់អាចយកឈ្នះលើគ្រោះកាចចង្រៃនោះ។ ប្រាកដហើយ ការសមាធិនឹងធ្វើចិត្តរឹងប៉ឹង ដើម្បីយល់ដឹងហេតុផលនៃបញ្ហា ឆ្ពោះទៅរកដំណោះស្រាយ។ នៅក្នុងករណីមានជម្ងឺដង្កាត់ ចិត្តស្ងប់ជួយធ្វើឱ្យមានឡើងការ

ព្យាបាលមួយកាន់តែឆាប់ឡើង។ ដោយការអង្វករ អំណាចអភិធម្មជាតិ (កម្លាំងក្រៅខ្លួន) ដើម្បីយកឈ្នះគ្រោះកាចមិនមែនជាដំណោះស្រាយសមរម្យដើម្បីបញ្ចប់សេចក្តីទុក្ខនោះទេ។ យើងត្រូវតែជញ្ជឹងគិតដោយស្ងប់ស្ងាត់ថាគ្រោះកាចចង្រៃគឺជារបស់អ្នកទាំងអស់ ដែលកើតមកនៅលើពិភពលោក



មន្តស្នេហ៍ និងអំពើអាបធ្មប់មិនមានឥទ្ធិពលអ្វីលើ
អ្នកដែលមានកម្លាំងផ្លូវចិត្តរឹងប៉ឹង



នេះ និងគិតថា អ្វីដែលកើតឡើងចំពោះយើង យើងត្រូវតែសង្កេតពិនិត្យមើលប្រកបដោយហេតុផល ធ្វើដូច្នេះយើងអាចរកឃើញដំណោះស្រាយសមហេតុសមផលមួយ។ នេះមិនមែនស្ថិតនៅលើវាសនានោះទេ ពោលគឺវាបង្ហាញថា បុគ្គលម្នាក់ៗ ដោយប្រើសម្មាវាយាមៈ (សេចក្តីព្យាយាមត្រូវ) អាចបញ្ចៀសខ្លួនគេពីគ្រោះកាចចង្រៃបាន។

## រូបបដិមា ទឹកមន្ត អំបោះមន្ត គ្រឿងទេវមន្ត និងវត្ថុស័ក្តិសិទ្ធិ

សង្គមមនុស្សជាទូទៅ ត្រូវបានទទួលការអប់រំកាន់តែប្រសើរក្នុងពេលបច្ចុប្បន្ននេះ ជាងនៅក្នុងអតីតកាល ប៉ុន្តែជំនួសឱ្យការរីកចម្រើនធំធេង ដែលសម្រេចបាននៅក្នុងវិស័យវិទ្យាសាស្ត្រ មនុស្សជាច្រើននៅតែរងគ្រោះ ពីសេចក្តីភ័យខ្លាច មន្ទិលសង្ស័យ និងអសន្តិសុខ។ ហេតុផលជាឫសគល់នៃសភាពចិត្តទាំងនេះ កើតចេញមកពីអវិជ្ជា វិចិកិច្ឆា និងតណ្ហា។ ដោយសារតែអវិជ្ជា មិនដឹងពីការមិនកើតមានអត្តាតួខ្លួនជានិរន្ត យើងជឿលើអាត្មន ហើយជំនឿនេះ បណ្តាលឱ្យមានតណ្ហា។ យើងពោរពេញទៅដោយតណ្ហាមិនចេះស្កប់ស្កល់ និងសេចក្តីភ័យខ្លាចពីការបាត់បង់អ្វីមួយដែលមានសព្វថ្ងៃ។ យើងភ័យខ្លាចថា យើងនឹងត្រូវគេធ្វើទុក្ខទោស និងភ័យខ្លាចថាយើងនឹងជួបប្រទះសំណាងមិនល្អ។ ដូច្នេះ យើងធ្វើអ្វីខ្លះ? តាមសភាវគតិ យើងងាកទៅរកជំនឿព្រលឹងនិយមអតីតរបស់យើង ហើយពឹងផ្អែកលើគ្រឿងវេទមន្តនិងវត្ថុស័ក្តិ-

សិទ្ធិដើម្បីការពារយើង។ ព្រះពុទ្ធទ្រង់សម្តែងយ៉ាងច្បាស់ថា ឧបករណ៍ខាងក្រៅមិនខ្លាំងគ្រប់គ្រាន់ ដើម្បីការពារអ្នកទាំងឡាយណា ដែលមានចិត្តទន់ខ្សោយ និងច្របូកច្របល់។ សន្តិសុខតែមួយគត់របស់យើង គឺត្រូវពឹងផ្អែកទៅលើចំណេះដឹងអំពីសច្ចៈរបស់យើង និងការយល់ដឹងអំពីធម្មជាតិពិតនៃអត្តាតួខ្លួនរបស់យើង ព្រមទាំងបាតុភូតផ្សេងៗទៀត។ នៅពេលណាមួយយើងយល់ដឹងថាគ្មានសភាវៈពិតនៅក្នុងអត្តាតួខ្លួន ដែលអាចត្រូវបានទទួលទុក្ខទោស ពេលនោះយើងផុតពីគ្រោះថ្នាក់និងជំនឿជឿជាក់ក្នុងខ្លួន។ គ្មានទុក្ខទោសណាអាចបៀតបៀនអ្នកមិនមានសេចក្តីភ័យខ្លាច មិនអត្តទត្ថបុគ្គល និងមិនមានមោហៈ សេចក្តីវង្វេងបានឡើយ។

ទោះបីយ៉ាងណាក៏ដោយ វាមិនមានន័យថា ព្រះពុទ្ធសាសនាស្តីបន្ទោសការប្រើប្រាស់គ្រឿងឧបករណ៍សាសនា ដូចជា បន្ទោងព្រះពុទ្ធរូប ដើម្បីផ្តល់ឱ្យយើងនូវអារម្មណ៍មិនមានទុក្ខភ័យ។ មហាបុរសជាច្រើនបានរកឃើញវត្ថុអាចរំសាយទុក្ខព្រួយ ផ្តល់ផាសុកភាព ដោយជញ្ជឹងគិតដោយយកចិត្តទុកដាក់ទៅលើព្រះពុទ្ធរូបស្ងប់ស្ងៀម។ នាយករដ្ឋមន្ត្រីទីមួយរបស់ឥណ្ឌាលោក **ណេរូ** បានមានប្រសាសន៍ថា នៅពេលអង់គ្លេសបានដាក់គុកលោក ប្រភពតែមួយគត់ដែលផ្តល់ឱ្យលោកនៅជាសុខ គឺព្រះពុទ្ធរូបតូចមួយ ដែលគាត់យកទៅជាមួយគាត់។ ពិតមែនហើយ រូបបដិមាខ្លួនឯងមិនមានកម្លាំងអំណាចមន្តអាគមអ្វីទេ។ ប៉ុន្តែ អ្វីដែលបដិមាតំណាងឱ្យ គឺព្រះពុទ្ធគុណដ៏ធំធេង ដែលព្រះអង្គគង់នៅយ៉ាងស្ងប់ស្ងៀម និងមិនធ្វើឱ្យប៉ះពាល់បានដោយការប្រហារដែលសត្រូវធ្វើមកលើព្រះអង្គ ហើយព្រះពុទ្ធបដិមាជានិមិត្តរូបដែលរំលឹកលោក ណេរុ អំពីកម្លាំងរបស់គាត់ផ្ទាល់ ហើយកម្លាំងនេះអាចប្រឈមមុខតទល់ជាមួយភាពមិនអនុគ្រោះយ៉ាងស្ងប់ស្ងៀម។ យើងក៏អាចយកព្រះពុទ្ធរូប ឬអក្សរចារឹកនៃព្រះសូត្រទៅតាមខ្លួនផងដែរ ដើម្បីឱ្យយើងមានជំនឿចិត្ត។ ព្រះសូត្រជាច្រើនបញ្ចប់ដោយការសុំសេចក្តីសុខថា **"ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជ័យមង្គលកើតមានដល់ខ្ញុំ"** ឬ **"សូមសិរីសួស្តីទាំងឡាយ ចូរមានដល់ខ្ញុំ"**។ នេះបង្ហាញថា ជាពុទ្ធសាសនិកមិនជឿទៅលើកម្លាំងអំណាចព្រលឹងនិយមរបស់ព្រះពុទ្ធបដិមា ឬវត្ថុស័ក្តិសិទ្ធិនោះទេ ប៉ុន្តែវត្ថុទាំងនោះចាត់ទុកថាជាជំនួយប៉ុណ្ណោះ ដែលអាចជួយយើងឱ្យទទួលបានជំនឿចិត្តនៅក្នុងខ្លួនរបស់យើង។



ដូចគ្នានេះដែរ ពុទ្ធសាសនិកខ្លះក៏បានទៅវត្តអារាមផងដែរ ដើម្បីយកទឹកមន្តនិងខ្សែអំបោះដែលបានសូត្រព្រះសូត្រដាក់ ប្រកបដោយសមាធិដ៏ធំ។ ទាំងនេះក៏ផ្តល់កម្លាំងនិងទំនុកចិត្តបែបចិត្តសាស្ត្រផងដែរ ទៅឱ្យអ្នកប្រើប្រាស់ពីព្រោះវត្ថុទាំងនោះរំលឹកគេអំពីសច្ចៈ ដែលព្រះសូត្រត្រូវបានបន្លឺសូរតាមមាត់ហើយនិងសច្ចៈនោះរំលឹកឡើងវិញពីឱវាទរបស់ព្រះសម្មាសម្ពុទ្ធ។



វត្ថុស័ក្តិសិទ្ធិរំលឹកយើងអំពីកម្លាំងនៃសច្ចភាព

## ជម្ងឺ

ថ្មីៗនេះ មានការរិះគន់ជាច្រើន ចោទប្រកាន់មេដឹកនាំព្រះពុទ្ធសាសនា ថាមេដឹកនាំទាំងនោះ ហាក់ដូចជាមិនយកចិត្តទុកដាក់ដល់អ្នកទាំងឡាយណា ដែលមានជម្ងឺ។ បណ្តាអ្នករិះគន់ទាំងឡាយបង្ហាញប្រាប់ថា សាវ័កនៃសាសនា



ដទៃទៀតពិតជាបានធ្វើដំណើរពីមន្ទីរពេទ្យមួយទៅកាន់មន្ទីរពេទ្យមួយ ដើម្បីជួយសម្រាលទុក្ខអ្នកជម្ងឺសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ ក្តីកង្វល់ដល់អ្នកជម្ងឺបែបនេះ គឺជាអ្វីមួយដែលគួរឱ្យសរសើរដោយពិត។ នៅក្នុងប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា ឧបាសកនិមន្តព្រះសង្ឃទៅសួរសុខទុក្ខអ្នកជម្ងឺ ហើយព្រះសង្ឃលើសពីមានបំណងផ្តល់នូវការជួយសង្គ្រោះ ចំពោះការគោរពនេះទៅទៀត។ តាមពិតព្រះសង្ឃមានចំណេះវិជ្ជា ដែលចេះថ្នឹកខាងថ្នាំបុរាណ ជារឿយៗ គេសុំការជួយសង្គ្រោះ ហើយព្រះសង្ឃថែមទាំងផ្តល់ការជួយសង្គ្រោះដោយស្ម័គ្រចិត្ត។

ដោយសារតែពុទ្ធសាសនិកជាច្រើន មិនថ្នឹកនៅក្នុងសាសនារបស់ខ្លួន ទប់ទល់នឹងស្មៀតល្បិចរបស់អ្នកកាន់សាសនាដទៃ ភាពមិនចាប់អារម្មណ៍បែបនេះ គ្រាន់តែអាចឱ្យអ្នកកាន់សាសនាដទៃទាញយកប្រយោជន៍ពីស្ថានភាព ដើម្បីធ្វើឱ្យពួកគេផ្លាស់សាសនា។ អ្នកកាន់សាសនាដទៃ ថែមទាំងបានទៅធ្វើការសន្យាជួយសង្គ្រោះយ៉ាងសន្ធឹក ដោយបំភ័យជនរងគ្រោះរបស់ពួកគេ ដោយពាក្យគម្រាមកំហែងថាធ្លាក់នរក ហើយតាមមធ្យោបាយនេះទទួលបានអ្នកផ្លាស់សាសនា។ ព្រះសង្ឃពុទ្ធសាសនា មិនចង់ធ្វើអំពើបែបនេះទេ។ ទោះបីយ៉ាងណាក៏ដោយ ពេលគេនិមន្ត ព្រះសង្ឃនឹងនិមន្តដោយសុខចិត្តតាម

សមាជិកគ្រួសារនិងមិត្រភ័ក្តិជិតស្និទ្ធ ទៅសួរសុខទុក្ខអ្នកជម្ងឺ មិនត្រឹមតែនៅក្នុងមន្ទីរពេទ្យទេ ថែមទាំងនៅផ្ទះទៀតផង។



ការសូត្រព្រះបរិត្តអាចជួយឱ្យធូរស្រាលពីជម្ងឺ

ជម្ងឺគឺជាចំណែកមួយសំខាន់នៃជីវិតប្រចាំថ្ងៃរបស់យើងនៅក្នុងពិភពលោកនេះ ហើយយើងគួរតែគ្រប់គ្រងវាដោយសម្រួល។ ទោះបីយ៉ាងណាក៏ដោយ នៅក្នុងព្រឹត្តការណ៍មានជម្ងឺដង្កាត់កើតមានដល់បុគ្គលណាម្នាក់ គេគួរតែវាងវៃ ក្រៅអំពីសម្រាកព្យាបាលដោយឱសថទំនើប គួរតែនិមន្តព្រះសង្ឃ



ប្រារព្ធពិធីប្រោះព្រំជយមង្គលតាមបែបសាសនា ដើម្បីឱ្យអ្នកជម្ងឺធូរស្បើយឆាប់រហ័ស។ នៅពេលទទួលបានបណ្តុំចិត្តសមរម្យ ការប្រារព្ធពិធីបែបនេះនឹងប្រើការគ្របដណ្តប់ផ្នែកអារម្មណ៍ស្មារតី និងចិត្តសាស្ត្រយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅលើអ្នកជម្ងឺ។ ហេតុដូចនេះ ជួយបង្កើនល្បឿនការធូរស្បើយជម្ងឺរបស់គាត់។ ជាពិសេស នៅពេលជម្ងឺកើតមានរួមទាំងមានឥរិយាបទផ្លូវចិត្តរបស់អ្នកជម្ងឺ ការប្រារព្ធពិធីរបស់ព្រះសង្ឃ នឹងអាចកាន់តែមានប្រយោជន៏បំផុត។ នៅក្នុងតួយ៉ាងដែលជំនឿជឿថា ជម្ងឺត្រូវបានបង្កឡើងដោយឥទ្ធិពលខាងក្រៅមិនល្អមួយចំនួន ឬបិសាចអសុរកាយ ពិធីប្រោះព្រំជយមង្គលតាមបែបសាសនា បង្កើតឥរិយាបទចិត្តសាស្ត្រដ៏ល្អ ដែលជាផលអាចសាយភាយការរញ្ជួយញ័រមានគុណប្រយោជន៏នៅក្នុងរាងកាយ ដើម្បីជម្រុញការធូរស្បើយឆាប់រហ័ស។ ទោះបីយ៉ាងណាក៏ដោយ ដូចអ្នកកាន់ព្រះពុទ្ធសាសនាប្រកបដោយការយោគយល់ យើងមិនគួរធ្វើឱ្យខ្លួនយើងចុះចាញ់ជំនឿដែលមានការភាន់ច្រឡំដែលថា បិសាចអសុរកាយគឺជាបុព្វហេតុតែមួយគត់បណ្តាលឱ្យកើតជម្ងឺរបស់យើង។ ព្រះពុទ្ធឱវាទ ÷ "**ពេលណាក៏ដោយ អ្នកទាំងឡាយមានជម្ងឺផ្លូវកាយ ចូរអ្នកទាំងឡាយកុំបណ្តាលឱ្យចិត្តរបស់អ្នកទាំងឡាយឈឺជាមួយផង**" គឺពិតជាមានលក្ខណៈពិតតាមសភាវៈពិត។ បើតាមពុទ្ធឱវាទនេះ យើងត្រូវប្រើប្រាជ្ញាស្មារតីនិងសុភវិនិច្ឆ័យរបស់យើងដើម្បីស្វែង

រកការប្រុងប្រយ័ត្នផ្នែកវេជ្ជសាស្ត្រសមរម្យដើម្បីព្យាបាលជម្ងឺរបស់យើង ជាជាងធ្វើឱ្យខ្លួនយើងបង្អោនទៅរកជំនឿអភិធម្មជាតិជាអ្នកបង្កើតឱ្យមានជម្ងឺ ។



សមាធិអាចបង្កើតសេចក្ដីសុខនៅខាងក្នុង

## ការស្លាប់

មានសេចក្ដីរំពឹងថា មនុស្សគឺអាចស្លាប់និងស្លាប់ ។ ទោះបីយ៉ាងណាក៏ដោយ មនុស្សមួយចំនួនធំអាចទទួលយកការបំបែក ឬសេចក្ដីភ័យខ្លាចអំពីអ្វីដែលកើតឡើងបន្ទាប់ពីការស្លាប់ ។

មានសេចក្ដីងងឹតងងល់ច្រើនសន្ធឹកសន្ធាប់ណាស់ កើតមានក្នុងសន្តានអ្នកកាន់ព្រះពុទ្ធសាសនាទាក់ទងនឹងការស្លាប់ថា មនុស្សថែមទាំងផ្លាស់ប្ដូរសាសនា ធ្វើដូច្នេះគេអាចទទួលបានពិធីបុណ្យបូជាសព "សមរម្យ" ដើម្បីធានាបានថានឹងបានឋានសួគ៌តាមផ្លូវកាត់ ។ គេដឹងថា គ្រួសារទាំងឡាយត្រូវបានកាត់ផ្ដាច់បំបែកចេញ ពីព្រោះបុត្រធីតាដែលកាន់សាសនាមួយ រហ័សរហួន



ផ្លាស់ប្ដូរសាសនា មាតាបិតាដែលកំពុងមានជម្ងឺធ្ងន់ធ្ងរនៅលើគ្រែ ។ បុត្រធីតាអ្នកកាន់ព្រះពុទ្ធសាសនាមួយចំនួន មិនអាចធ្វើអ្វីមួយបានទេ ពីព្រោះពួកគេមិនបានរៀនសូត្រពីអ្វីត្រូវធ្វើក្នុងឋានៈជាពុទ្ធសាសនិកពិតប្រាកដ ។ ហេតុនេះវាមានសារៈសំខាន់ណាស់ សម្រាប់មាតាបិតាអ្នកកាន់ព្រះពុទ្ធសាសនា ត្រូវប្រាប់ពីគោលបំណងប្រាថ្នារបស់ពួកគាត់ ឱ្យបុត្រធីតាបានដឹងច្បាស់លាស់ និងបង្រៀនបុត្រធីតានូវអ្វីដែលត្រូវធ្វើក្នុងឋានៈជាពុទ្ធសាសនិក នៅក្នុងព្រឹត្ត-ការណ៍នៃមរណភាពរបស់ពួកគាត់ ។ ប្រជាជនអវិជ្ជាជាច្រើន មានប្រពៃណីដែលហាមប៉ះពាល់ប្រឆាំងនឹងមរណភាព ហើយមិនចូលចិត្តចូលរួមពិធីបុណ្យសព ដោយគិតថាវានឹងនាំឱ្យមានសំណាងមិនល្អដល់ខ្លួនពួកគេ ។

ក្មេងៗត្រូវរៀនពីមនុស្សវ័យជំទង់ថា ការស្លាប់គឺជាផ្នែកធម្មជាតិមួយនៃការកើត ។ ពួកគេត្រូវរៀនកុំភ័យខ្លាចក្តារមឈូស និងសាកសពខុសពីធម្មតា ។ ពួកគេត្រូវដឹងពីអ្វីដែលប្រកបដោយសុភវិនិច្ឆ័យ ត្រូវធ្វើនៅឯពិធីបុណ្យសព ។ ប្រសិនបើប្រការនេះមិនបានធ្វើ ហើយនៅពេលមរណភាព (ការស្លាប់) កើតមានឡើងយុវវ័យក្មេងៗ និងមានការខាតបង់និងស្ថិតនៅក្រោមការប្រោសប្រណីរបស់អ្នកកាន់សាសនាគ្មានសីលធម៌ ដែលជាអ្នកប្រើប្រាស់ឱកាសនេះដើម្បីធ្វើឱ្យពួកគេផ្លាស់ប្ដូរនូវជំនឿ ឬឱ្យពួកគេចំណាយប្រាក់កាសច្រើនសន្ធឹកសន្ធាប់ទៅលើការប្រារព្ធពិធីខុសនិងគ្មានប្រយោជន៍ ។

ដំបូង យើងត្រូវយល់ដឹងពីឥរិយាបទអ្នកកាន់ព្រះពុទ្ធសាសនាចំពោះការស្លាប់។ តាមបែបវិទ្យាសាស្ត្រនិយាយថា "ជីវិត" គឺជាការកើតនិងរលត់បន្តគ្នាឥតឈប់ឈរ។ កោសិកានៅក្នុងសារពាង្គកាយរបស់យើងកំពុងស្លាប់ឥតឈប់ឈរ និងជំនួសមកវិញដោយកោសិកាថ្មីៗ។ ព្រោះហេតុនេះ ការកើត និងការស្លាប់ប្រព្រឹត្តទៅគ្រប់ៗខណៈ។ បាតុភូតនៃការស្លាប់គឺគ្រាន់តែជាការបញ្ចប់បែបរឿងល្ខោននៃការកើតជាបន្តបន្ទាប់តែប៉ុណ្ណោះ។ ប៉ុន្តែ ទីបញ្ចប់មិនទៀងទាត់នោះទេ (អនិច្ចំ)។ តាមពិតដំណើរការបន្ទាប់មួយក្រោយសេចក្តីស្លាប់ ការកើតកើតមានឡើង។ ដូច្នេះនៅក្នុងព្រះពុទ្ធសាសនា ការស្លាប់មិនហៅថាការសម្រាកខាងក្រៅខ្លួន ដើម្បីស្ថិតនៅក្នុងទ្រូងនៃអាទិទេពបង្កើតលោកនោះទេ ប៉ុន្តែជាការបន្តនៃការកើតនៅក្នុងទម្រង់មួយផ្សេងទៀត។ ដូច្នេះ គ្មានការចាំបាច់ណាមួយត្រូវខ្លាចការស្លាប់នោះទេ។ នៅក្នុងទស្សនៈទាក់ទងនឹងបញ្ហានេះ ព្រះពុទ្ធទ្រង់មិនបានដាក់បញ្ញត្តិលើពិធីបុណ្យតាមបែបសាសនាជាក់លាក់ណាមួយទេ ទាក់ទងការយកសាកសពទៅបូជា។ គេគួររំកិលផ្លាស់ទីសាកសពមនុស្សស្លាប់ដោយកិត្តិយស ហើយគេគួរតែប្រព្រឹត្តសមរម្យ ក្រៅពីការគោរពដើម្បីជាការរំលឹកទៅលើអ្វីដែលអ្នកដែលបានស្លាប់បានធ្វើនៅពេលគាត់នៅរស់។ ទង្វើក្នុងអតីតកាលរបស់គាត់ (កម្ម) នឹងកំណត់នូវអ្វីដែលជីវិតអនាគតរបស់គាត់ត្រូវទទួល។





មនុស្សគ្រប់រូបដែលកើតមក តែងស្លាប់ និងបដិសន្ធិជាថ្មី

យើងត្រូវមានកតញ្ញូតាធម៌ ដឹងគុណចំពោះទង្វើអ្វីក៏ដោយដែលអ្នកដែលបានស្លាប់ទៅ បានធ្វើចំពោះយើងនៅក្នុងកាលកន្លងទៅ។ សេចក្តីទុក្ខសោកកើតមាននៅក្នុងចិត្តរបស់យើង ពីព្រោះនរណាម្នាក់ដែលយើងស្រឡាញ់បានធ្វើដំណើរចេញចាកពីយើង (ស្លាប់)។ នៅពេលយើងជួបជុំគ្នានៅជុំវិញសាកសពនៃអ្នកដែលយើងស្រឡាញ់ ជាមិត្រភ័ក្តិនិងជាសាច់ញាតិ យើងឃើញធូរស្បើយនៅក្នុងក្រុមនៃអ្នកដទៃទៀត ដែលចែករំលែកទុក្ខព្រួយសាមញ្ញរបស់យើង និងជាអ្នកផ្តល់ការគាំទ្រសីលធម៌ដល់យើង នៅពេលយើងមាន

សេចក្តីទុក្ខសោក។ ពិធីបុណ្យតាមវប្បធម៌ខុសៗគ្នា ដែលយើងប្រារព្ធធ្វើមានប្រយោជន៍ណាស់ ពីព្រោះជួយឱ្យយើងរំសាយនូវសេចក្តីទុក្ខព្រួយតិចទៅ។

## ការវះកាត់ពិនិត្យសាកសព

សម័យបច្ចុប្បន្ននេះ នៅក្នុងករណីទាំងឡាយដែលការស្លាប់បានកើតឡើងនៅក្នុងកាលៈទេសៈពិសេសជាចាំបាច់ត្រូវធ្វើការស៊ើបអង្កេតបន្ថែម វាបានក្លាយជាកិច្ចការសាមញ្ញ សម្រាប់មន្ទីរពេទ្យត្រូវធ្វើការវះកាត់ពិនិត្យសាកសពនៃអ្នកដែលបានស្លាប់ ដើម្បីអះអាងបញ្ជាក់ពីដើមហេតុនៃការស្លាប់។ ជួនកាល សាច់ញាតិជំទាស់មិនឱ្យធ្វើបែបនេះ ដោយគិតថាវាជាការប្រមាថ ដែលត្រូវវះកាត់ឬធ្វើឱ្យខូចសាកសព ដែលគេចាត់ទុកថាជាពិសិដ្ឋវត្ថុ (វត្ថុដែលគេគោរព)។ បើនិយាយចំពោះពុទ្ធសាសនិក គួរតែគ្មានហេតុផលសាសនាដែលត្រូវជំទាស់នឹងការវះកាត់នេះនោះទេ។ តាមពិត ប្រសិនបើការវះកាត់ពិនិត្យសាកសពអាចជួយអ្នកដែលរស់នៅដោយផ្តល់ឱ្យសមាជិក ដែលអាជីពខាងវេជ្ជសាស្ត្រជាមួយនឹងពត៌មានបន្ថែមទៀត អាចជួយពួកគេអាចព្យាបាលជម្ងឺ គេគួរតែគិតថាវាជាអំពើបុណ្យមួយផ្នែកដែរ។ ដូចដែលបានពោលមកពីខាងដើម រូបរាងកាយគឺគ្មានអ្វីក្រៃលែងជាងការផ្សំបញ្ចូលគ្នានៃធាតុទាំងឡាយ (មហាភូតរូប៤) ដែលនឹងត្រូវបំបែកជាបំណែកតូចៗទៅវិញនៅពេលស្លាប់។ ដូច្នេះ គ្មានហេតុផលអ្វីត្រូវជឿថា ព្រលឹងវិញ្ញាណនៃអ្នកដែលស្លាប់ទៅនឹង



អាក់អនចិត្ត ប្រសិនបើរាងកាយត្រូវបានគេប្រើប្រាស់ក្នុងគោលបំណងវិទ្យាសាស្ត្រ។ គេអាចធានាឱ្យយើងផ្សេងទៀតថា បណ្ឌិតវេជ្ជបណ្ឌិតនិងអ្នកជំនួយការវេជ្ជសាស្ត្រទាំងឡាយ មានទំនួលខុសត្រូវខ្ពស់ និងក្រមសីលធម៌វិជ្ជាជីវៈ ហើយពួកគេចាប់កាន់សាកសពដោយសេចក្តីគោរពសម្បើមក្រៃលែង ដែលជាកាតព្វកិច្ចរបស់គ្រូពេទ្យ ដូច្នេះសាច់ញាតិមិនចាំបាច់ព្រួយបារម្ភជ្រុលហួសហេតុអំពីបញ្ហានេះទេ។ មានមនុស្សមួយចំនួនស្ម័រតែប្តេជ្ញាថានឹងបរិច្ចាគសាកសពរបស់ពួកគេ បន្ទាប់ពីគេស្លាប់ទៅមន្ទីរពេទ្យ សម្រាប់ឱ្យនិស្សិតផ្នែកវេជ្ជសាស្ត្រសិក្សាកាយវិភាគវិទ្យា។

នៅក្នុងទំនាក់ទំនងនេះ គេចាត់ទុកថាជាអំពើនៃការបំពេញបុណ្យដ៏ខ្ពង់ខ្ពស់បំផុតសម្រាប់ពុទ្ធសាសនិក ក្នុងការបរិច្ចាគផ្នែកនៃរាងកាយរបស់ពួកគេបន្ទាប់ពីស្លាប់ ដូច្នេះអ្នកដទៃអាចទទួលបានផលប្រយោជន៍ពីពួកគេ។ នៅក្នុងអតីតជាតិ ព្រះពុទ្ធទ្រង់បានបរិច្ចាគរាងកាយរបស់ព្រះអង្គផ្ទាល់ ដើម្បីជាគុណប្រយោជន៍ដល់អ្នកដទៃ។ ព្រះអង្គបានឱ្យព្រះនេត្រ ព្រះលោហិត និងសាច់ស្រស់របស់ព្រះអង្គ ហើយនៅក្នុងឱកាសមួយព្រះអង្គបានបូជារាងកាយទាំងមូលរបស់ព្រះអង្គ ដើម្បីជួយសង្គ្រោះជីវិតជនដទៃទៀត។ ព្រះអង្គយល់ជាក់ច្បាស់អំពីបញ្ហានេះ ពោលគឺការបរិច្ចាគសរីរាង្គសម្រាប់ជាគុណប្រយោជន៍

ដល់អ្នកដទៃ នាំមកនូវអំពើបុណ្យដ៏ធំធេង និងត្រូវបានគេលើកទឹកចិត្តយ៉ាងខ្លាំង។



ការបរិច្ចាគសរីរាង្គកាយ

## ពិធីបុណ្យសព

នៅក្នុងបណ្ដាសង្គមមានវប្បធម៌និងអារ្យធម៌រីកចម្រើនពិធីបុណ្យសពត្រូវបានគេចាត់ទុកថាជាពិធីដ៏សោកសៅនិងឱឡារិក។ ពិធីបុណ្យសពគួរតែជាពិធីឱឡារិក ហើយគេគួរប្រារព្ធធ្វើឱ្យបានសមស្រប ដូចនៅក្នុងសង្គមមានអារ្យធម៌រីកចម្រើន។



មានអបិយជំនឿ ដែលបានផ្សព្វផ្សាយពាសពេញមួយក្នុងចំណោមប្រជាជនមួយចំនួនដែលថា វាជាសំណាងអាក្រក់ដែលនាំយកសាកសពមកចូលក្នុងគេហដ្ឋាន ប្រសិនបើមនុស្សម្នាក់បានស្លាប់នៅក្នុងទីដទៃ។ យើងត្រូវបានគេចងភ្ជាប់ឱ្យបង្ហាញការគោរពរបស់យើង ចំពោះការធ្វើឱ្យនឹកឃើញឡើងវិញនូវបុគ្គលដែលបានស្លាប់ទៅហើយ ដើម្បីប្រព្រឹត្តចំពោះសាកសពដោយការគោរពសមរម្យដោយផ្ដល់ឱ្យដល់សាកសពនូវការបូជាសមរម្យមួយ។ ទោះបីសាកសពត្រូវបាននាំយកមកគេហដ្ឋាន ឬមិននាំយកមកក៏ដោយ អាស្រ័យលើអ្វីដែលងាយស្រួលបំផុតសម្រាប់សមាជិកគ្រួសារនៃសព។ នៅក្នុងទំនាក់ទំនងនេះ យើងគប្បីពោលផងដែរថា គួរតែគ្មានការភ័យខ្លាច ឬប្រពៃណីហាមប៉ះពាល់ ដោយគោរពការចាប់កាន់សាកសពអ្នកស្លាប់ដោយដៃ។ មនុស្សមួយចំនួនភ័យខ្លាចមិនហ៊ានប៉ះសាកសព ដោយគិតថាពួកគេអាចត្រូវបានប្រឈមមុខជាមួយ "សំណាងអាក្រក់"។ ប្រសិនបើប្រការនេះជាការពិត វេជ្ជបណ្ឌិតនិងគិលានុប្បដ្ឋាកគិលានុប្បដ្ឋាយិកា គួរជាមនុស្សគួរឱ្យអាណោចអធ័មបំផុតលើលោកនេះ។ បើយើងពិតជាមានបំណងចង់លើកតម្កើងការធ្វើឱ្យនឹកឃើញឡើងវិញនូវបុគ្គលដែលបានស្លាប់របស់យើង យើងគួរតែផ្ដួតទឹក និងប្ដូរសំលៀកបំពាក់ថ្មីដល់សាកសព និងមិនទុកសាកសពឱ្យអ្នកដទៃនៃក្រុមហ៊ុនស៊ី

ឈ្លក់ខ្មោច ធ្វើជំនួសយើងឡើង។ ចូរចងចាំថា អបិយជំនឿ អវិជ្ជា និង សេចក្តីភ័យខ្លាចមិនសមហេតុសមផល នាំមកនូវសំណាងមិនល្អច្រើនជាង កតញ្ញូតា សេចក្តីស្រឡាញ់ និងភាពរីករាយ។

ផ្ទុយពីជំនឿពេញនិយម ពិធីបុណ្យសពដែលអ៊ូអរអឹកធឹក ធំដុំ និង ពេលខ្លះសម្ញែងហួសហេតុឬធំសម្បើម ដែលចំណាយប្រាក់កាសរាប់ពាន់ដុល្លា ទៅលើវត្ថុមិនចាំបាច់ និងដែលជារឿយៗត្រូវបានចាត់ថាជា "ពិធីបុណ្យរបស់ ពុទ្ធសាសនិក"ធម្មតា តាមពិត មិនមែនជាពិធីបុណ្យរបស់ពុទ្ធសាសនិកទាល់តែ សោះ។ វាជាការភាន់ច្រឡំទាំងស្រុង ក្នុងការចូលរួមពិធីបុណ្យទាំងអស់នេះ ជាមួយព្រះពុទ្ធសាសនា។ ពិធីទាំងនោះគ្រាន់តែជានិរន្តរកម្ម (ការធ្វើឱ្យនៅ មានជាប់រហូត) នៃទំនៀមទម្លាប់និងប្រពៃណីដែលមានតាំងពីបុរាណ បាន ទុកឱ្យបន្តពីជំនាន់មុន ដែលគេកំពុងកាន់ដោយងងឹតងងល់។ នៅពេលមើល ឃើញពិធីបុណ្យសពបែបនេះ ប្រជាជននៃជំនឿផ្សេង តែងតែមានចម្ងល់ថាតើ អ្វីដែលពួកគេកំពុងឃើញគឺជាដំណើរការប្រារព្ធពិធីបុណ្យសប្បាយរីករាយ ឬ ពិធីបុណ្យសពឱឡារិក។

ជាញឹកញាប់ណាស់ គេតែងតែប្រគុំតន្ត្រីសម្លេងខ្លាំងៗនៃតន្ត្រីឱឡារិក អំឡុងពេលដំណើរការពិធីបុណ្យសព។ ហេតុនេះ គេគួរអាចទទួលបានការ ចាប់អារម្មណ៍ថា ពិធីត្រូវបានរៀបចំច្រើនតែបង្ហាញទៅខាងក្រៅ នៃភាព



សម្បូរណ៍ទ្រព្យធនស្តុកស្តម្ភ ជាជាងដើម្បីបង្ហាញសេចក្តីទុក្ខសោកពិតឥតក្លែង ក្លាយនិងការគោរពចំពោះអ្នកដែលស្លាប់ទៅ។ ទោះបីព្រះពុទ្ធសាសនាមិន ប្រឆាំងជំទាស់នឹងការធ្វើឱ្យមានជាប់នៅរហូតនូវពិធីបុណ្យបែបប្រពៃណី ដូច ដែលតាំងពីយូរណាស់មកហើយ ដែលពិធីទាំងនោះមិនជំទាស់ប្រឆាំងនឹង ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺគេមានអារម្មណ៍ថា ពិធីបុណ្យខាតពេល វេលា មិនផ្តល់ផលចំណេញ (មិនសន្សំសំចៃ) និងមិនចាំបាច់ ដែលមិនផ្តល់ ប្រយោជន៍ដល់អ្នកដែលស្លាប់ទៅ ទាំងអ្នកដែលនៅរស់ គួរជាពិធីធ្វើឱ្យអស់ ជំនឿនិងត្រូវលះបង់ចោលទាំងស្រុង។ ជាតួយ៉ាង ការប្រារព្ធធ្វើជាប្រពៃណី នៃការដុតក្រដាសប្រាក់ ក្រដាសមាសក្រដាសប្រាក់ និងផ្ទះក្រដាសនិមិត្តរូប ដែលរៀបចំឡើងដោយអះអាងថា សម្រាប់ជាប្រយោជន៍ដល់អ្នកដែលស្លាប់ ទៅ ដើម្បីប្រើប្រាស់នៅក្នុងជីវិតក្នុងបរលោក ពោលគឺលោកខាងនាយ គឺពិត ជាមិនមែនជាការប្រារព្ធរបស់ពុទ្ធសាសនិកនោះឡើយ។ ទោះបីយ៉ាងណាក៏ ដោយ ប្រសិនបើវាជួយគេប្រកបដោយចិត្តសាស្ត្រ ដើម្បីធ្វើឱ្យតិចទៅនូវ សេចក្តីសោកសង្រេងរបស់គេ ដោយធ្វើឱ្យគេគិតថា គេកំពុងធ្វើអ្វីៗជា ប្រយោជន៍ដល់អ្នកដែលស្លាប់ទៅ វាមិនមានទុក្ខទោស ប៉ុន្តែយ៉ាងណាក៏ដោយ គេមិនគួរប្រកាន់តឹងឬជឿថា វាអាចជួយអ្នកដែលស្លាប់ទៅតាមមធ្យោ- បាយណាមួយនោះឡើយ។

ព្រះពុទ្ធសាសនាមិនប្រឆាំងជំទាស់នឹងសហគមន៍ផ្សេងៗ ដែលប្រារព្ធពិធីបុណ្យសពខុសៗគ្នា ដែលស័ក្តិសមសម្រាប់តំបន់នីមួយៗនិងពេលវេលា។ ប៉ុន្តែរឿងដែលសំខាន់បំផុតគឺថា ពួកវាត្រូវតែទទួលយកបាននិងអនុវត្តជាវប្បធម៌ប្រពៃណី។ ពិធីបុណ្យដែលភ្ជាប់នឹងពិធីបុណ្យសពបែបពុទ្ធសាសនា គួរតែជាពិធីបុណ្យសាមញ្ញធម្មតា ឱឡារិក ផ្តល់កិត្តិយស និងមានអត្ថន័យ។ នៅក្នុងប្រទេសជាច្រើន គេនិមន្តព្រះសង្ឃពុទ្ធសាសនាទៅគេហដ្ឋានអ្នកដែលស្លាប់ដើម្បីប្រារព្ធពិធីបុណ្យសាសនា មុនពិធីបុណ្យសព។ ការបូជាផ្កាភ្ញី និងការដុត



ការដុតក្រដាសមិនអាចឧទ្ទិសផលដល់អ្នកស្លាប់បានទេ



ក្រដាសមាសក្រដាសប្រាក់ខ្លះ និងទៀន ធូប គឺគេអាចទទួលយកបានថាជាការប្រារព្ធធ្វើបែបសាសនា នៅក្នុងឱកាសបែបនេះ។

ជាទំនៀមទម្លាប់ជាសញ្ញានៃការគោរព សម្រាប់មិត្រភ័ក្តិនិងសាច់ញាតិដើម្បីផ្ញើកម្រងផ្កាសម្រាប់ពិធីបុណ្យសព។ ទាំងនេះ ដោយពេញចិត្តជាង គួរតែរៀបចំបញ្ជូនទៅឱ្យដល់គេហដ្ឋានមិនឱ្យមុនថ្ងៃត្រង់ មុនពិធីបុណ្យសពម៉្យាងទៀត នៅថ្ងៃដ៏សោកសៅ ខ្លួនវា ផ្កាទាំងនោះអាចស្វិតស្រពោន។ ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើមានផ្លាកដំណឹងមរណភាព ពិសេសមានសរសេរថា "មិនទទួលផ្កាភ្ញី" ដូច្នេះ សំណើរនេះគួរតែគោរពដោយតឹងរ៉ឹង។

ដោយសារតែសាច់ញាតិមានគំនិតខុសគ្នា ស្តីពីពិធីបុណ្យសព មានការមិនព្រមព្រៀងជាច្រើនអំពីពិធីបុណ្យសមរម្យដែលត្រូវប្រារព្ធ។ គេជារឿយៗបានសួរសំនួរទាំងឡាយខាងក្រោម ÷

១. តើគួរបូជា ឬកប់?

២. បើបូជា តើគេធ្វើអ្វីខ្លះជាមួយអដ្ឋិធាតុ?

៣. តើយើងត្រូវប្រើក្តារមឈូសប្រភេទណា?

៤. តើយើងត្រូវស្លៀកពាក់សំលៀកបំពាក់កាន់ទុក្ខពណ៌អ្វី ខ្មៅឬស?

៥. តើត្រូវប្រើទៀនពណ៌អ្វី ក្រហមឬស?

៦. តើសពត្រូវរក្សាទុកប៉ុន្មានថ្ងៃ មុនបូជាឬកប់?

៧. តើកំណត់ការចំណាយអ្វីខ្លះ សម្រាប់ពិធីបុណ្យសព?

គ្រប់សំនួរទាំងអស់នេះ គេអាចឆ្លើយយ៉ាងសាមញ្ញដូចខាងក្រោមនេះ÷

ពិធីបុណ្យសពត្រូវតែសាមញ្ញ ប្រកបដោយភាពមួម៉ៅនិងក្តីកង្វល់តិចបំផុត ប៉ុន្តែប្រកបដោយកិត្តិយស។ ប្រហែលជារឿងដែលមានសុភវិនិច្ឆ័យបំផុតដែលត្រូវធ្វើ គប្បីសម្រាប់សមាជិកប្រញាប់ប្រញាល់នៃគ្រួសារនិងមិត្រភ័ក្តិជិតស្និទ្ធត្រូវមានការពិភាក្សាមិនផ្លូវការមួយ អំពីវិធីល្អបំផុតដើម្បីរៀបចំពិធីកម្មបុណ្យសព ក្នុងភាពអាចបញ្ជាក់បាន ជាមួយការប្រតិបត្តិជាទូទៅប្រកបដោយកិត្តិយសស្ងប់ស្ងាត់ និងគ្មានការជួបប្រទះការចំណាយមិនចាំបាច់។ ប្រសិនបើពួកគេមិនអាចដោះស្រាយបញ្ហានេះដោយខ្លួនគេផ្ទាល់ទេ អ៊ីចឹងគេត្រូវបានផ្តល់យោបល់ថា កិច្ចការនេះគួរទុកឱ្យអ្នកស៊ីឈ្នួលកប់ខ្មោចមានកិត្តិ-សព្ទ ព្រោះគេអាចយល់ដឹងគ្រប់កិច្ចការទាំងអស់ ដែលត្រូវធ្វើ ហើយដូច្នេះនឹងខិតខំយ៉ាងច្រើននិងយកទំនួលខុសត្រូវចេញពីដៃសាច់ញាតិ។ គេក៏អាចស្វែងរកដំបូន្មានផងដែរពីព្រះសង្ឃដែលគួរឱ្យគោរព ជាអ្នកពិតជាអាចណែនាំគ្រួសារសពចំពោះអ្វីដែលអាចជាវិធីល្អបំផុត ដើម្បីរៀបចំពិធីបុណ្យសព ក្នុងអត្តចរិតសមរម្យ ដែលស្របនឹងមាគ៌ាជីវិតបែបព្រះពុទ្ធសាសនា។ គេត្រូវតែចងចាំថា យូរណាស់មកហើយ ពិធីបុណ្យពុទ្ធសាសនាដែលមានជាប់ទាក់ទងគ្មានក្បួនច្បាប់មិនអាចបត់បែនបាន ដែលត្រូវរក្សាយ៉ាងតឹងរ៉ឹងនោះទេ។ នៅ



ក្នុងបញ្ហានេះ ដូចនៅក្នុងបញ្ហាទាំងអស់ យើងតែងតែត្រូវព្យាយាមប្រតិបត្តិតាមព្រះពុទ្ធឱវាទ ដើម្បីរក្សាការទប់ឱ្យនៅជាកណ្តាល និងការទទួលខុសត្រូវក្នុងអ្វីក៏ដោយដែលយើងធ្វើ គ្មានការបង្កទុក្ខទោសដល់អ្នកដទៃ។ ប្រសិនបើយើងអាចប្រើប្រាស់ឱកាស ដើម្បីផ្តោតអារម្មណ៍ប្រកបដោយកតញ្ញូតាធមិ ការងារល្អធ្វើដោយអ្នកដែលស្លាប់អំឡុងពេលគាត់នៅរស់ ដើម្បីចងចាំថាយើងខ្លួនឯងនឹងត្រូវឃ្លាតចាកលោក(ស្លាប់) នៅថ្ងៃណាមួយនិងចងចាំថាយើងគួរតែធ្វើអ្វីក៏ដោយដែលល្អ ដែលយើងអាចធ្វើសម្រាប់អ្នកដែលស្លាប់ ពេលយើងនៅរស់ ដូច្នេះការបរិច្ចាគរបស់យើងអាចមានន័យនិងមានកិត្តិយស។

តើសំលៀកបំពាក់អ្វី ដែលសមរម្យសម្រាប់ពិធីបុណ្យសព? នៅក្នុងព្រះពុទ្ធសាសនា គេផ្តល់យោបល់ឱ្យយើងស្លៀកពាក់សុភាព សមរម្យ និងមធ្យមមិនហួសហេតុ។ គ្មានក្បួនច្បាប់វិន័យមិនអាចបត់បែនបាន ចំពោះអ្វីដែលយើងគួរស្លៀកពាក់នៅឯពិធីបុណ្យសពនោះទេ ប៉ុន្តែភាពថ្លៃថ្នូរតម្រូវថាយើងគួរស្លៀកពាក់សំលៀកបំពាក់ស្រងូតស្រងាត់ និងមិនត្រូវប្រើប្រាស់គ្រឿងអលង្ការ ក្នុងការសម្តែងសេចក្តីគោរពចំពោះអារម្មណ៍គ្រួសារសព និងចេញពីសេចក្តីគោរព ចំពោះការធ្វើឱ្យនឹកឃើញឡើងវិញដល់អ្នកដែលស្លាប់ទៅ។ស្ត្រីដែលកាន់ទុក្ខ ប្រហែលជាអាចពាក់ចិញ្ចៀនអាពាហ៍ពិពាហ៍ឬចិញ្ចៀនភ្ជាប់ពាក្យរបស់នាង។ ជាការប្រសើរ គួរស្លៀកពាក់សំលៀកបំពាក់ដែលមាន

ពណិខ្មៅ ស ប្រផេះ ឬពណិដែលទាក់ទងដទៃទៀតមួយចំនួន ប៉ុន្តែបញ្ហាត្រូវបន្សល់ទុកទាំងស្រុងដល់បុគ្គលនិងការចាប់អារម្មណ៍ចំពោះភាពសមហេតុសមផលរបស់គាត់ ទោះជា "ពណិខ្មៅ" ក៏ដោយ ជាធម្មតា គេទទួលស្គាល់ថាជានិមិត្តរូបអាចទទួលយកបាន សម្រាប់ការកាន់ទុក្ខ ។

តើរយៈពេលប៉ុន្មាន ដែលសាកសពគួររក្សាទុកមុននឹងបូជា ឬកប់? យើងជាអ្នករស់នៅក្នុងអាកាសធាតុក្តៅហើយសើម គួរយល់ដឹងថាការបំបែកធាតុប្រព្រឹត្តទៅឆាប់រហ័សណាស់ និងយល់ដឹងថា វាជាការខ្វះអនាម័យ ដែលទុកសាកសពក្នុងរយៈពេលយូរពេក ។ ក្រៅពីនេះ វាជាការដាក់លទ្ធភាពធំធេងមួយដល់សាច់ញាតិនៃសព ក្នុងការត្រូវអត់ទ្រាំជាមួយភាពនៅជិតសាកសពរយៈពេលយូរជាងពេលដែលចាំបាច់ ។ អ្នកកាន់ទុក្ខខ្លះផងដែរ ចេញពីសេចក្តីសោកសៅទុក្ខព្រួយផ្លូវចិត្តខ្លាំងក្លាថា គេត្រូវតែអត់ទ្រាំ ប៉ុន្តែគួរកុំធ្វើហួសហេតុ ឬគួរកុំជម្រុញទឹកចិត្ត ។ នៅពេលគេមិនអាចតម្រូវពិតប្រាកដជាក់ស្តែងចំពោះរយៈពេលដែលសាកសពត្រូវរក្សាទុក ជាការប្រកបដោយគតិបណ្ឌិតគួរកុំពន្យាពេលពិធីបុណ្យដែលមិនចាំបាច់ ។ តាមធម្មតា វាហាក់ដូចជាយកជាការបានបំផុត ត្រូវទុកចន្លោះរយៈពេលប្រហែលមួយថ្ងៃឬពីរថ្ងៃសម្រាប់ការរៀបចំពិធីបុណ្យសព និងសម្រាប់ការផ្តល់ដំណឹងដល់មិត្រភ័ក្តិឬញាតិមិត្ត ។



នៅថ្ងៃបុណ្យសព ពិធីកម្មរបស់ព្រះសង្ឃពុទ្ធសាសនា ត្រូវបាននិមន្តម្តងទៀត ដើម្បីប្រារព្ធពិធីកម្មសាសនាចាំបាច់មួយនៅគេហដ្ឋាន និងនៅកន្លែងទីបញ្ចុះសព ។ វាជាកិច្ចប្រារព្ធធ្វើក្នុងចំណោមប្រជាជនខ្លះ ក្នុងការសែនជ្រូកនិងមាន់ខ្វៃ ជាការសែននិមិត្តរូបសម្រាប់អ្នកដែលស្លាប់ទៅ ។ កិច្ចប្រារព្ធធ្វើបែបនេះ មិនត្រូវបានលើកទឹកចិត្តឱ្យធ្វើនៅក្នុងព្រះពុទ្ធសាសនាទេ ពីព្រោះវាជាប់ពាក់ព័ន្ធការសម្លាប់សត្វស្លូតបូតគ្មានកំហុស ។ ការផ្តល់ការសែនបូជាយញ្ញដល់អ្នកដែលស្លាប់ទៅ គឺពិតជាជំទាស់នឹងពាក្យប្រៀនប្រដៅនៃព្រះពុទ្ធ ព្រះអង្គប្រកបដោយមេត្តាចិត្ត និងគេគួរតែលះបង់ចោល ។ ការបូជាផ្កាភ្ញីជាការសម្តែងការគោរពរាប់អានសាមញ្ញ ជាមួយនឹងការដុតធូបនិងទៀន អាចបំពេញសេចក្តីត្រូវការបានថាជាការបូជាជានិមិត្តរូប ។

## ការកប់ និងការបូជាសព

ពុទ្ធសាសនិកជាច្រើន បានសួរថាតើបុគ្គលដែលស្លាប់ទៅ គេគួរកប់ ឬបូជា ។ ព្រះពុទ្ធសាសនា ជាសាសនាមានសេរីភាព អាចបត់បែនបានលើបញ្ហានេះ ។ គ្មានក្បួនច្បាប់វិន័យមិនអាចបត់បែនបាននោះទេ ទោះបីនៅក្នុងប្រទេសកាន់ព្រះពុទ្ធសាសនាមួយចំនួន ការបូជាសពអ្នកដែលស្លាប់ទៅគឺជាការបដិបត្តិដែលសាមញ្ញអាចទទួលយកបាន ។ ការជ្រើសរើសវិធីសាស្ត្រមួយឬវិធីសាស្ត្រ

មួយផ្សេងទៀត គួរឱ្យស្របនឹងបំណងចុងក្រោយរបស់អ្នកដែលស្លាប់ទៅ ឬគួរទុកសេរីភាពក្នុងការសម្រេចឱ្យញាតិដែលជិតជាងគេ។

ទោះបីយ៉ាងណាក៏ដោយ នៅក្នុងរបៀបគិតសម័យទំនើប ការបូជាជាទម្រង់អនាម័យមួយនៃការយកសាកសពទៅចោល គេគួរជម្រុញនិងលើកទឹកចិត្ត។ ជាមួយការរីកចម្រើននៅក្នុងមាត្រដ្ឋានសុខភាព និងការកើនចំនួនប្រជាជនយ៉ាងឆាប់រហ័សស្អីគេនោះ ដីដែលអាចប្រើប្រាស់បានកំពុងក្លាយទៅជាខ្វះខាត ដូច្នេះហើយគេឱ្យដំបូន្មានឱ្យបែរមករកការបូជាសពវិញ និងទុកការប្រើប្រាស់ដីមានតម្លៃសម្រាប់ការរស់នៅ ជំនួសឱ្យការពពាក់ពពូនជាមួយថ្មដាក់នៅក្បាលផ្នូរចំនួនច្រើនសន្ធឹកសន្ធាប់។

ទោះបីការកប់ ឬការបូជាសពក្តី គេបានដឹងថា ប្រជាជនខ្លះ សម្រាប់ហេតុផលមនោសញ្ចេតនា ចូលចិត្តដាក់កម្មសិទ្ធមានតម្លៃផ្ទាល់ខ្លួនរបស់អ្នកដែលស្លាប់ ទៅក្នុងក្តារមឈូសក្នុងសេចក្តីសង្ឃឹមនិងជំនឿថា អ្នកដែលស្លាប់ទៅអាចទទួលបានផលប្រយោជន៍ពីវា ដោយមធ្យោបាយណាមួយ។ វាជាការបញ្ឆោតឱ្យយល់ខុស ឬជំនឿខុសដែលសង្ឃឹមជឿជាក់ថា ការបូជាឬដុតកម្ម-សិទ្ធិបែបនេះ ទុកជាយ៉ាងណាក៏ដោយ អាចទទួលបានជាអំពើបុណ្យកុសល។ ជំនួសឱ្យការដាក់វត្ថុបែបនេះនៅក្នុងក្តារមឈូសឬឈាបនស្ថាន វាអាចកាន់តែមានប្រយោជន៍និងសមហេតុសមផល ក្នុងការឱ្យកម្មសិទ្ធិមានប្រយោជន៍ផ្ទាល់



ខ្លួន ដូចជា សំលៀកបំពាក់ ទ្រនាប់ជើង និងរបស់របរជាច្រើនដទៃទៀត ទៅអ្នកក្រីក្រ និងអ្នកក្រខ្សត់ ជាអំពើបុណ្យ ដែលផ្តល់ផលប្រយោជន៍ដល់អ្នកនៅរស់ និងអ្នកដែលស្លាប់ទៅ។ សេចក្តីភ័យខ្លាច ដែលថាមនុស្សខ្លះមានការគោរពចំពោះការប្រើប្រាស់កម្មសិទ្ធរបស់អ្នកដែលស្លាប់ គឺគ្មានន័យនិងរក្សាទុកមិនបាន។

## ការយកសំណល់អដ្ឋិធាតុទៅចោល

សំនួរមួយដែលគេតែងតែសួរ គឺថាតើគួរកប់អដ្ឋិធាតុ ដាក់ដំកល់រក្សាទុកនៅក្នុងចេតីយ៍ ឬក៏យកសំណល់អដ្ឋិធាតុទៅរាយបាចសាចទៅក្នុងសមុទ្រ។ ព្រះពុទ្ធទ្រង់មិនបានបន្សល់ទុកការណែនាំជាក់លាក់ណាមួយលើបញ្ហានេះទេ ពីព្រោះព្រះអង្គមានព្រះទ័យចង់ឱ្យយើងយល់ដឹងថា រាងកាយគឺគ្មានអ្វីទាំងអស់លើសពីការរួមបញ្ចូលគ្នារវាងវត្ថុធាតុរាងកាយ ដែលចុងក្រោយនឹងត្រឡប់ទៅជាក្រុមៗនៃធាតុដដែល បន្ទាប់ពីស្លាប់។ ព្រះពុទ្ធទ្រង់បានបង្រៀនថាទម្រង់វត្ថុធាតុរាងកាយផ្សំឡើងពីធាតុដី ទឹក ភ្លើង និងខ្យល់។ នៅពេលស្លាប់មានតែធាតុពីរប៉ុណ្ណោះដែលនៅសល់ គឺធាតុដីនិងធាតុទឹក ដែលនៅពេលក្លាយទៅជាផេះ គឺគ្មានព្រលឹងវិញ្ញាណទៀតទេ។ ដោយសារយើងចាត់ទុកសំណល់ (អដ្ឋិធាតុ) ថាជាអ្នករំលឹកដល់អ្នកដែលស្លាប់ជាអ្នកដែលយើងធ្លាប់បានស្រឡាញ់ យើងប្រព្រឹត្តចំពោះសំណល់អដ្ឋិធាតុដោយសេចក្តីគោរព។ ប៉ុន្តែ

យើងមិនត្រូវជាប់ចិត្ត ឬថែមទាំងគិតថា តាមមធ្យោបាយណាមួយសំណល់អដ្ឋិធាតុ នឹងមានការជាប់ទាក់ទងជាមួយអ្នកដែលបានស្លាប់ទៅហើយនោះទេ។ ព្រះពុទ្ធសាសនាបង្រៀនថា វិញ្ញាណចាកចេញភ្លាមៗបន្ទាប់ពីស្លាប់ ហើយទៅចាប់បដិសន្ធិនៅក្នុងរូបធម៌ថ្មីមួយទៀតនៅកន្លែងផ្សេង។



ការចម្រើនព្រះបរិត្តអាចជួយឱ្យធូរស្បើយពីសេចក្តីទុក្ខ



ការបដិបត្តិរក្សាសំណល់អដ្ឋិធាតុ របស់អ្នកដែលស្លាប់ គឺវិលទៅរកអតីតកាលដើមដំបូងរបស់យើង។ នៅសម័យនោះ នៅពេលប្រជាជនមានជំនឿទៅលើព្រលឹងមិនចេះស្លាប់ វាជាការបដិបត្តិ ដូចករណីជនជាតិអេស៊ីបរក្សាសំណល់អដ្ឋិធាតុ ក្នុងសេចក្តីសង្ឃឹមថា ព្រលឹងអ្នកដែលស្លាប់ទៅ ដោយហេតុនោះ អាចរក្សាការទាក់ទងជាមួយអ្នកដែលនៅរស់។ ផ្នូរសម្រាប់ដាក់និងចេតិយ៍ដ៏ធំសម្បើមបានត្រូវគេសាងសង់ជុំវិញសំណល់អដ្ឋិធាតុ។ ប៉ុន្តែការបដិបត្តិបែបនេះ បានត្រូវត្រៀមទុកសម្រាប់តែឥស្សរជនសំខាន់ៗ ដូចជា ព្រះមហាក្សត្រនិងមេដឹកនាំសាសនាប៉ុណ្ណោះ។ សំណល់អដ្ឋិធាតុប្រជាជនសាមញ្ញជាធម្មតា ត្រូវបានគេបំផ្លាញចោល តាមវិធីសមរម្យ។

ផ្ទុយពីការបដិបត្តិបែបនេះ មានការបដិបត្តិមួយផ្សេងទៀត គឺការគោរពបុព្វបុរស ដែលថាការរស់នៅបានរក្សាការទាក់ទងជាមួយអ្នកដែលស្លាប់ ដោយប្រតិបត្តិតាមការបដិបត្តិពិធីកម្មជុំវិញអ្នកដែលស្លាប់។ នេះជាមូលហេតុនៃការបដិបត្តិរក្សាសំណល់អដ្ឋិធាតុនៅក្នុងកោដ្ឋ ឬប្រដាប់សម្រាប់ដាក់ផ្សេងទៀត ដើម្បីទុកគោរពបូជា ពោលគឺ ការបដិបត្តិដែលគេនៅតែបន្តអនុវត្តសូម្បីតែសព្វថ្ងៃនេះក្តី។

ប្រជាជនមួយចំនួន មានបំណងប្រាថ្នាចង់រក្សាទុកអដ្ឋិធាតុនៅក្នុងអគារសំណង់មួយ ចំណែកឯប្រជាជនដទៃផ្សេងទៀតកប់អដ្ឋិធាតុដែលនៅ

សល់។ វិធីសាស្ត្រមួយផ្សេងទៀត គឺបោះបាចសាចអដ្ឋិធាតុទៅក្នុងសមុទ្រ ឬទន្លេ។ វិធីសាស្ត្រនេះ ជាទំនៀមទម្លាប់ទូទៅរបស់ប្រជាជនហិណ្ឌូ ដែលមានជំនឿថា សំណល់អដ្ឋិធាតុ ចុងក្រោយបំផុតនឹងរួមគ្នាឡើងវិញ ជាមួយកម្លាំងបង្កើតថ្មីដោយខ្លួនឯង។

គ្មានទុក្ខទោសក្នុងការអនុវត្តតាមវិធីសាស្ត្រណាមួយ ក្នុងចំណោមវិធីសាស្ត្រទាំងអស់នេះនោះទេ ប៉ុន្តែគេមិនត្រូវចាត់ទុកវិធីសាស្ត្រទាំងនេះ ថាជារបស់ពុទ្ធសាសនិកចំៗ ឬដែលពុទ្ធសាសនិកត្រូវធ្វើតាមនោះទេ។ យើងមិនគួរមានគំនិតខុសផងដែរ ដែលថាដោយរក្សាអដ្ឋិធាតុនៅក្នុងទីកន្លែងស័ក្តិសិទ្ធិ ដូចជា ព្រះវិហារ អ្នកដែលស្លាប់ទៅ នឹងមាន "**សុវត្ថិភាព**" ពីការត្រូវទទួលវិបាកនៃកម្មរបស់គាត់។ ជាប្រការត្រឹមត្រូវដែលចាត់ទុកជាសញ្ញានៃការគោរព ក្នុងការរំលឹកឱ្យនឹកឃើញឡើងវិញដល់អ្នកដែលស្លាប់ ប៉ុន្តែគ្មានអ្វីផ្សេងទៀតទេ។ នៅក្នុងព្រះពុទ្ធសាសនា របៀបយកអដ្ឋិធាតុរបស់អ្នកដែលស្លាប់ទៅចោល គឺសម្រាប់គ្រួសារអ្នកដែលស្លាប់សម្រេចចិត្ត ដើម្បីឱ្យសេចក្តីថ្លៃថ្នូរនិងសុជីវធម៌កើតមានឡើង។

## រយៈពេលនៃការកាន់ទុក្ខ

នៅពេលនរណាម្នាក់ស្លាប់ ញាតិមិត្តជិតស្និទ្ធ ជាធម្មតា បានចំណាយពេលវេលាសម្រាប់កាន់ទុក្ខ។ ថេរវេលានៃការកាន់ទុក្ខ អាស្រ័យលើចំណង



ទាក់ទង ដែលបានកើតមានរវាងអ្នកដែលស្លាប់និងសមាជិកគ្រួសារអ្នកដែលស្លាប់។ អំឡុងពេលនេះ គេស្លៀកពាក់ស្រគត់ស្រគំ ចៀសវាងពីទម្រង់ភាគច្រើននៃការជប់លៀងសប្បាយរីករាយ និងការកំសាន្តសប្បាយ។ អ្នកខ្លះគេស្លៀកពាក់ពណ៌ស ខ្លះទៀតពណ៌ខ្មៅ និងអ្នកខ្លះមួយចំនួនមិនចូលរួមពិធីរៀបអាពាហ៍ពិពាហ៍ ឬការប្រារព្ធពិធីផ្សេងៗ រហូតរយៈពេលមួយឆ្នាំបានកន្លងផុតទៅ ជាដើម។ ទាំងនេះមិនមែនជាការរក្សារបស់ពុទ្ធសាសនិកចំៗនោះទេ ពីព្រោះធម៌វិន័យរបស់ពុទ្ធសាសនិកមិនសំដៅដល់ដូចនោះៗទេ។ ទោះបីយ៉ាងណាក៏ដោយ សហគមន៍ផ្សេងៗបានអភិវឌ្ឍពិធីបុណ្យខ្លះ ដោយផ្អែកលើការបដិបត្តិវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេ ហើយការបដិបត្តិទាំងនេះ ត្រូវបានទទួលយកថាជា "របស់ពុទ្ធសាសនិក"។ គោលបំណងរបស់ពួកគេ គឺគោរពដល់ការនឹករលឹកអ្នកដែលស្លាប់ទៅ ដើម្បីរំលឹកគេអំពីភាពអាចនឹងស្លាប់របស់គេ និងដើម្បីអភិវឌ្ឍការយល់ដឹងកាន់តែទូលាយនៃសម្បជញ្ញផ្លូវចិត្ត។ ប្រសិនបើធ្វើតាមប្រកបដោយបញ្ញា និងប្រសិនបើការបដិបត្តិទាំងនេះមិនជ្រៀតជ្រែករំខានដល់ដំណើរជីវិតចាំបាច់ ដូច្នេះក្នុងនាមជាពុទ្ធសាសនិកយើងគ្មានហេតុផលនឹងប្រឆាំងជំទាស់ការបដិបត្តិទាំងនោះទេ។ **មាគ៌ាព្រះពុទ្ធសាសនា គឺជាមជ្ឈិមាបដិបទា ពោលគឺមាគ៌ាកណ្តាលគ្រប់រឿងរ៉ាវហេតុការណ៍ទាំងអស់**។

## ពិធីបុណ្យក្រោយពិធីបុណ្យសព និងពិធីបុណ្យខួប

បន្ទាប់មក មានសំនួរជាច្រើនអំពីពិធីបុណ្យក្រោយពិធីបុណ្យសព។ ប្រជាជនមួយចំនួន ប្រារព្ធពិធីទក្ខិណានុប្បទាន ឧទ្ទិសដល់អ្នកដែលស្លាប់នៅថ្ងៃទីប្រាំពីរ សែសិបប្រាំបួន និងមួយរយថ្ងៃ ចំណែកអ្នកផ្សេងទៀត ក្រៅពីថ្ងៃទីប្រាំពីរ ប្រារព្ធធ្វើបន្ទាប់ពីបីខែ និងមួយឆ្នាំ។ គេពិតជាមានជំនឿថា ព្រលឹងអ្នកដែលស្លាប់អាចត្រឡប់មកក្នុងអំឡុងពេលជាក់លាក់ទាំងនេះ។ ប៉ុន្តែ ថាតើ



សំណល់អដ្ឋិធាតុអាចបន្សាត់ទៅក្នុងទឹកសមុទ្រ



យើងជឿឬអត់ គឺមិនសំខាន់ទេ។ ពិធីកម្មសាសនាសមហេតុសមផល ក្នុងការធ្វើឱ្យនឹកឃើញឡើងវិញដល់អ្នកដែលស្លាប់ ដែលមិត្រភក្តិនិងសាច់ញាតិជួបជុំគ្នាចែករំលែកបទពិសោធន៍ផ្លូវចិត្ត និងផ្តល់ការគាំទ្រផ្នែកសីលធម៌ ដើម្បីកាត់បន្ថយទុក្ខព្រួយគ្រួសារអ្នកស្លាប់ គឺធ្វើឱ្យខ្ពង់ខ្ពស់។ ប៉ុន្តែគ្មានភាពចាំបាច់ដើម្បីទទួលថាពិធីកម្មត្រូវតែប្រារព្ធក្នុងកាលបរិច្ឆេទជាក់លាក់ឡើយ។ គេអាចទទួលយកកាលបរិច្ឆេទណាមួយ ដែលសមគួរដល់អ្នកទាំងអស់ដែលជាប់ពាក់ព័ន្ធ សម្រាប់ប្រារព្ធពិធីកម្មនោះ។

**ឆេងម៉េង** ឬ **ទិវាសែនផ្លូវដូនតា** មិនមែនជាពាក្យឬការបដិបត្តិរបស់ពុទ្ធសាសនិកនោះទេ។ ប៉ុន្តែវាពិតជាកាយវិការដ៏ល្អ នៅពេលសហគមន៍ទាំងមូលទុកដោយឡែក សម្រាប់ទិវាពិសេសមួយ ដើម្បីចងចាំអ្នកទាំងឡាយដែលស្លាប់ទៅ ដោយចូលរួមគ្នាសម្អាតផ្នូរដូនតា និងបូជាផ្កាភ្ញី ជាសញ្ញានៃការគោរព។ នេះអាចបង្ហាញថា កូនចៅអ្នកដែលស្លាប់ទៅហើយគឺជាកូន ជាចៅ និងបានបំពេញកាតព្វកិច្ចរបស់ពួកគេចំពោះជីដូនជីតា។ ព្រះពុទ្ធសាសនា មិនជំទាស់ដោយមធ្យោបាយណាមួយ ចំពោះទង្វើដ៏ល្អនេះនៅក្នុងការដឹងគុណនិងការចងចាំ ដែលអាចធ្វើឱ្យយុវវ័យក្មេងៗបង្ហាញសេចក្តីគោរពចំពោះចាស់ទុំរបស់ពួកគេ និងអាចធ្វើឱ្យយុវវ័យប្រឹងធ្វើឱ្យល្អដូចឬល្អជាង នូវការបដិបត្តិបែបប្រពៃណីដ៏ល្អនៃការគោរពបូជា ចំពោះព្រលឹងដូនតាដែលបាន

ស្លាប់ទៅហើយ ។ ទោះបីយ៉ាងណាក៏ដោយ សេចក្ដីភ័យខ្លាច ដែលថាប្រជាជនមួយចំនួនបានបង្កើតការគិតនៅក្នុងចិត្តនៃប្រជាជនស្លូតត្រង់ថា អ្នកទាំងឡាយដែលស្លាប់ទៅនឹងត្រឡប់មកធ្វើទុក្ខបុកម្នេញ និងរំខានដល់សមាជិកគ្រួសារ ប្រសិនបើពួកគេមិនបានប្រារព្ធធ្វើពិធីបុណ្យឱ្យ គឺគ្មានហេតុផល ។

## ការធ្វើទាន

វាជាការបដិបត្តិសាមញ្ញមួយ នៅក្នុងសហគមន៍ភាគច្រើន ក្នុងការធ្វើពិធីកម្មខាងសាសនាឧទ្ទិសចំពោះអ្នកដែលស្លាប់ ក្នុងអំឡុងពេលដែលបានរៀបរាប់ បន្ទាប់ពីពិធីបុណ្យសព ។ ការបដិបត្តិរបស់ពុទ្ធសាសនិក គឺត្រូវចូលរួមក្នុងការធ្វើនិងឱ្យទាន ព្រមទាំងឧទ្ទិសកុសលចំពោះអ្នកដែលបានស្លាប់ទៅ ។ ដើម្បីធ្វើកិច្ចការនេះ ញាតិសន្ដាននិងមិត្រភ័ក្ដិអ្នកដែលស្លាប់ទៅ តែងតែនិមន្តព្រះសង្ឃ និងប្រគេនទេយ្យវត្ថុ មានដូចជា ចង្ហាន់បិណ្ឌបាត និងគិលានភេសជ្ជៈ ( ថ្នាំពេទ្យ) ជាដើម ។ ការបូជាទាំងនេះ ដែលបរិច្ចាគដល់ហិតសុខផ្នែកសម្ភារៈនៃពិសិដ្ឋបុគ្គល គឺគេចាត់ទុកថា ជាអំពើបុណ្យ ។ ពុទ្ធសាសនិកដែលមានការចេះដឹង ក៏បានពង្រីកការបរិច្ចាគរបស់គេទៅដល់ស្ថាប័នសង្គហធម៌ អ្នកក្រខ្សត់ និងគម្រោងសំណង់សាសនា ( ព្រះវិហារ ជាដើម) ក៏ដូចជាបោះពុម្ពសៀវភៅធម៌ចែកជូនដោយឥតគិតថ្លៃដល់សាធារណជន ដើម្បីធ្វើឱ្យមានរហូតទៅនូវការនឹកឃើញដល់អ្នកដែលស្លាប់ទៅ ។ ទាយកទាយិកាដែលធ្វើទានបែបនេះ



ប្រកបដោយចិត្តបរិសុទ្ធ និងធ្វើឱ្យច្រើនឡើងនៃចិត្តជាកុសល ។ ពួកគេធ្វើអំពើកុសលទាំងនេះ ដើម្បីធ្វើឱ្យនឹកឃើញដល់អ្នកដែលស្លាប់ទៅ និងអភិវឌ្ឍទំ-ទាក់ទំនងផ្លូវចិត្តប្រកបដោយកុសលធម៌ជាមួយអ្នកដែលស្លាប់ទៅ ។ ប្រសិនបើអ្នកដែលស្លាប់ទៅ បានទៅកើតក្នុងទីឋានដ៏ប្រសើរ គឺបានទទួលតេជៈគឺបុណ្យ ( **ការឧទ្ទិសកុសល**) រឹតតែចម្រើនជាភិយ្យោភាព ។ ម្យ៉ាងទៀត បើអ្នកដែលស្លាប់ទៅមិនបានកើតក្នុងទីឋានដ៏ប្រសើរទេ អំពើបុណ្យនោះមិនឥតផល




បច្ច័យដែលបរិច្ចាគធ្វើទានជាប្រយោជន៍ដល់អ្នកស្លាប់

ទេ ពីព្រោះបុណ្យនោះនឹងជួយដល់អ្នកដែលនៅរស់ ដែលបានធ្វើឱ្យមានការគិតដ៏ល្អបែបនេះ ដើម្បីបានទៅដល់សេចក្ដីសុខផ្លូវចិត្តដ៏ក្រៃលែង។ ព្រះសង្ឃពុទ្ធសាសនា ទោះនៅក្នុងទីវត្តអារាមណាមួយក៏ដោយ នឹងជួយប្រកបដោយចិត្តរីករាយ ដល់សមាជិកគ្រួសារអ្នកដែលស្លាប់ទៅ ដោយសេចក្ដីគោរពចំពោះអ្វី ដែលចង់បានឱ្យធ្វើ ដើម្បីប្រារព្ធការធ្វើទានបែបនេះ។

## សន្និដ្ឋាន

គេសង្ឃឹមយ៉ាងក្លៀវក្លាថា មេដឹកនាំពុទ្ធសាសនាក្នុងស្រុករបស់យើង នឹងយល់ដឹងតាមពេលដ៏សមគួរ នៃការបដិបត្តិទូទៅដែលបានពោលរួចមកហើយ ដែលអវិជ្ជមាននៅក្នុងចរិតលក្ខណៈនិងអគតិ (សេចក្ដីលំអៀង) ដទៃទៀត ដោយមានបំណងដែលនឹងបង្កការកែទម្រង់ឱ្យមានប្រសិទ្ធិភាព ដូច្នេះការបដិបត្តិអ្វីក៏ដោយដែលកំពុងអនុវត្តដោយពួកយើង នឹងកាន់តែមានអត្ថ-ន័យច្រើនឡើង។ គេមានអារម្មណ៍ថាមេដឹកនាំរបស់យើង គួរតែធ្វើការពិនិត្យឡើងវិញជាមូលដ្ឋាននៃការបដិបត្តិសព្វថ្ងៃ និងទទួលស្គាល់សេចក្ដីត្រូវការបន្ទាន់ ដើម្បីបង្កើតឱ្យកើតឡើងការកែទម្រង់បែបនេះ តាមរយៈការអប់រំជាសាធារណៈនិងការផ្សាយជាសាធារណៈអាចធ្វើទៅបានយ៉ាងទូលំទូលាយបំផុតដែលដឹកនាំឆ្ពោះទៅរកទីបញ្ចប់។



## ពិនិត្យកែសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធដោយ

-ព្រះមហា **សៀង ទុន្ធី** សមណនិស្សិតថ្នាក់អនុបណ្ឌិត

- ភិក្ខុ **អ៊ុំ សត្ថា** សមណនិស្សិតថ្នាក់អនុបណ្ឌិត
- ភិក្ខុ **មួន វិចិត្រ** សមណនិស្សិតថ្នាក់អនុបណ្ឌិត
- ភិក្ខុ **ខ៉ាន ភាគ** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ

-ភិក្ខុ **វ៉ា ចន្ទបិន** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ

- សាមណេរ **ឆ្លិច មាស** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ
- សាមណេរ **ខិន ម៉ៅ** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ
- សាមណេរ សុខ ធារី សមណនិស្សិតថ្នាក់អនុបណ្ឌិត
- ឧបាសក **ម៉ៅ វ៉ាន** ឧបាសិកា **ធន់ សំបូរ** អតីតទីប្រឹក្សាឯកអគ្គរាជទូតកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា

## អ្នកបកប្រែ និងវាយកុំព្យូទ័រ

- ភិក្ខុ **ព្រុំ ស៊ីណា** (សញ្ញាតវីរិយោ)

រចនាក្របដោយភិក្ខុបញ្ញាវរោ **ស៊ុយ សុវណ្ណ**